ខេមរភាសា

ជ. ឈុំ

ចាងហ្វាងសាលារៀនឧបដ្ឋជីឡាគ្រេ

# ពាក្យ

## ភាសា - អក្ខរាវិរុទ្ធរបស់ពាក្យ

# VOCABULAIRE

## LANGAGE-ORTHOGRAPHE

បោះពុម្ពលើកទី ៥

ទុកសិទ្ធិ

TOUS DROITS RÉSERVÉS

ព.ស. ២៥០១ - គ.ស. ១៩៥៨

T. Watanabe le 23-2-59 à P. Penh

CA 11

ខេមរភាសា

ច. ឈុំ

អតីតចាងហ្វាងសាលារៀនព្រះអង្គអេង (ឧបដ្ឋជីឡាគ្រេ)

# ពាក្យ

ភាសា–អក្ខរាវិរុទ្ធរបស់ពាក្យ

បោះពុម្ពលើកទី ៤

ការផ្សាយរបស់

បណ្ណាគារ

រស្មីកម្ពុជា

ទុកសិទ្ធ

TOUS DROITS RÉSERVÉS

ព. ស. ២៥០០ គ. ស. ១៩៥៨

N· 2468

# CONSEIL DES MINISTRES

# PRAKAS

## LE MINISTRE DE L'ÉDUCATION NATIONALE ET DE LA JEUNESSE

Vu la Constitution du Royaume;

Vu le Traité Franco-Khmer en date du 8 Novembre 1949 et ses accords d'application;

Vu le Krâm n· 171-NS du 15 Avril 1946;

Vu le Kret n· 125-NS du 1er Juin 1950;

Vu le Procès-Verbal en date du 4 Août 1950 de la Commission pour Enseignement Primaire Khmer (1re sous-section)

ARRÊTE :

*Article unique.*— Le manuel rédigé en cambodgien par M. CH. CHHUM, Directeur de l'École Doudart de Lagrée, ayant pour titre ពាក្យ ភាសា. អក្ខរាវិរុទ្ធ របស់ពាក្យ», :VOCABULAIRE LANGAGE – ORTHOGRAPHE'', est ajouté à la liste des manuels et publications scolaires dont l'usage est autorisé dans les écoles publiques du Cambodge pour l'année scolaire 1950-1951.

Phnôm-Penh, le 31 Octobre 1950

*Signé :* PITOU DE MONTEIRO.

POUR COPIE CONFORME :

*Pour le Secrétaire Général*
*du Conseil des Ministres et p.o.*
*Le Secrétaire Général-Adjoint*
*Signé:* CHAI-THOUL

POUR AMPLIATION :

*Le chef de Cabinet,*
*Signé:* YEIM-YISINN.

លេខ-៥៤២៥ ក.

រដ្ឋមន្ត្រីក្រសួងសិក្សាធិការនិងយុវបរិយា

មកលោក អ៊ុំ-ឈុំ ចាងហ្វាងសាលាឌូដារដឺឡាគ្រេភ្នំពេញ

សូមជ្រាប ។

តបសំបុត្រលោកចុះថ្ងៃទី ២៤ កក្កដា គ.ស.១៩៥០

គណៈកម្មការរងបឋមសិក្សាខ្មែរ បានពិនិត្យមើលសៀវភៅ «ពាក្យ» ពីថ្ងៃ ៤ ខែសីហា គ.ស. ១៩៥០ យល់ព្រមបញ្ចូលសៀវភៅ «ពាក្យ» នេះ ទៅក្នុងពួកសៀវភៅសិក្សាតាមពាក្យលោកសុំ ដើម្បីជាប្រយោជន៍សាធារណៈដល់សាលារៀនទូទៅ ក្នុងព្រះរាជអាណាចក្រ ។

ប៉ុន្តែគណៈកម្មការនេះ សុំឲ្យលោកកែតម្រូវពាក្យខ្លះដែលបោះពុម្ពខុស ហើយនិងពាក្យខ្លះដែលពន្យល់ពុំបានពេញលេញ ដូចមានស្រង់ហើយកែតម្រូវតាមសេចក្ដីកត់ហេតុជាប់មកជាមួយនេះស្រាប់ ។

ខ្ញុំសូមសរសើរចំពោះលោក ដែលមានព្យាយាមតែងនិងរៀបរៀងសៀវភៅ «ពាក្យ» នេះ ឲ្យកើតឡើងដោយមានប្រាថ្នាចង់លើកដំកើងអក្សរសាស្ត្រ និងភាសាជាតិឲ្យបានថ្កុំថ្កើងរុងរឿងតទៅ ។

ភ្នំពេញថ្ងៃទី ២១ សីហា គ.ស. ១៩៥០

ពីទូដឹមុងតៀរ

---

ពាក្យខ្លះដែលបោះពុម្ពខុសហើយនិងសេចក្ដីខ្លះដែលពន្យល់ពុំបានពេញលេញកាលបោះពុម្ពលើកដំបូងនោះបានកែសម្រួលត្រឹមត្រូវហើយ តាមបង្គាប់ពីគណៈកម្មការរងបឋមសិក្សាខ្មែរ ។

*Phnom-Penh, 24 Juin 1950*

*Monsieur le Directeur,*

En retour de votre gracieux souvenir : le manuel intitulé «Peak» dont vous avez bien voulu adresser à chacun de nous un éxemplaire, nous vous remercions sincèrement et infiniment.

Nous avons pris connaissance de votre livre avec intérêt et nous croyons qu'il nous sera un guide utile et sûr dans l'enseignement du vocabulaire Khmer.

Nous vous renouvelons nos remerciements, Monsieur le Directeur et nous ne manquerons pas de Communiquer la publication de cet ouvrage à tous nos camarades et élèves dans le but de contribuer à votre éclatant succès.

Veuillez agréer, Monsieur le Directeur, l'assurance de nos sentiments les plus respectueux et dévoués.

*P. le Personnel de l'Ecole Doudart de Lagrée.*

NONG-SONN

*Phnom-Penh, le 30 Juin 1950*

à Monsieur OUM-CHHUM,
*Directeur de l'Ecole Doudart de Lagrée,*
*Auteur du Manuel «PEAK»*

Monsieur,

Ce m'est un très grand plaisir de vous confirmer combien je suis sensible du don d'un livre intitulé «Péak» que vous avez bien voulu me destiner, et je vous en exprime tous mes sincères remerciements.

Étant à la portée de tout le monde, ce manuel rendra de grands services aux maîtres qui peuvent y puiser à volonté ce qu'ils écrivaient et parlaient avec tant de difficultés et hésitations.

Je tiens à vous préciser qu'il est, en notre pays peu d'esprit qui se préoccupe réellement du sort de la littérature. Ainsi, conçu particulièrement en vue de pallier aux erreurs dues à la routine, ce manuel ne présente que d'incontestables avantages, d'autant plus qu'il constitue un guide sûr et précieux pour l'étude du vocabulaire et de l'orthographe Khmers.

Veuillez accepter l'expression de mes meilleurs sentiments.

MORY
*Inspecteur Ajoint*
*Enseignement Kandal,*

*Phnom-Penh, le 24 Octobre 1950*

à Monsieur OUM-CHHUM,

*Directeur de l'Ecole Doudart de Lagrée*

*à PHNOM-PENH*

Monsieur,

En vous accusant réception d'un manuel «PÉAK» dont vous êtes l'auteur,

J'ai l'honneur de vous prier de bien vouloir trouver ici ma très vive reconnaissance.

Cet ouvrage dont l'édition ne saurait que gagner l'agrément des lecteurs, présente, à mon avis, une très haute valeur éducative. Il est rare de trouver un livre de vocabulaire cambodgien qui, d'une part, s'adapte bien à tous les degrés culturels, et d'autre part, instruit les gens tout en les amusant.

Vous contribuerez, dans une large part, par votre constant souci d'être utile à la nation, au progrès tant du monde scolaire que du public studieux, et vous prendrez, à n'en pas douter, une place honorable parmi les auteurs Khmers au sein du cercle littéraire national.

Veuillez recevoir, Monsieur le Directeur, mes chaleureuses félicitations et mes souhaits de bons succès.

DIEP-PHÉAT

*Inspecteur-Adjoint Phnom-Penh.*

**MINISTERE DE L'ÉDUCATION NATIONALE**

**MINISTRE**

*Le 18 Février 1951*

Mon cher Directeur,

J'ai reçu votre livre et vous félicite chaleureusement de l'avoir rédigé. Il vient heureusement combler une lacune. Il sera pour nos collègues ainsi que pour tous ceux qui aiment l'orthographe exacte un guide précieux.

*Bien cordialement*

HUY-KANTHOUL

# អារម្ភកថា

សៀវភៅ “ ពាក្យ ” នេះ គាបឲ្យអ្នករៀនអក្សរនិងភាសាខេមរៈ ស្គាល់ពាក្យពិតប្រាកដ ចេះសរសេរត្រឹមត្រូវតាមអក្ខរៈ មិនសរសេរតាមតែបាន ឬ តាមតែចិត្តឥតមានគោលចារិកនោះឡើយ ។

ពាក្យដែលមានទាំងប៉ុន្មាន គឺខ្ញុំជ្រើសរើសរៀងតាមព្យញ្ជនៈ សំដៅយកតែពាក្យណាដែលត្រូវការប្រើញឹកញយ ហើយមានប្រយោជន៍ជាងគេទៀតផង មកធ្វើជាគោល ព្រមទាំងមានសេចក្ដីអធិប្បាយពន្យល់នូវពាក្យនីមួយៗ អំពីបទវេយ្យាករណ៍ អំពីអក្ខរវិរុទ្ធរបស់ពាក្យ ដែលច្រើននាំឲ្យគាន់ច្រឡំ ហើយនឹងរបៀបប្រើពាក្យទាំងនោះចងធ្វើជាឃ្លាចំរុះគ្នា បញ្ចូលពាក្យពិបាកផ្សេងៗ ច្រើនទៅទៀត ដើម្បីឲ្យអ្នកសិក្សាគ្រងគ្រាប់បានដោយងាយ ហើយមានពាក្យទំនឹមទំនៀមបុរាណដាក់ដោយសង្កាត់ទៀតផង ។

ខ្ញុំមានចិត្តសង្ឃឹមទុកជាមុនថា សៀវភៅបែបនេះដែលពុំទាន់មាននៅឡើយ នឹងពេញចិត្តដល់លោក - អ្នក - នាងជាអ្នកស្នេហាអក្សរនិងភាសាជាតិជាពុំខាន ។

តុលា គ.ស. ១៩៥០

ឃុំ

# អក្សរសង្ខេប

| | |
|---|---|
| កិ. | កិរិយាសព្ទ |
| កិ. វិ. | កិរិយាវិសេសន៍ |
| គុ. | គុណនាម |
| ន. | នាម |
| និ. ស. | និបាតសព្ទ |
| ម. បិ. | មើលថា |
| ម. សំ. | មគធៈទីធំសំស្រ្កឹត |
| អា. និ. | អាយតនិបាត |

១ខាងសព្ទ

## ក - ក៏ - ករ

ក= កមនុស្ស - កសាងចេតិយ - កកើតជាភូមិ ។

ក៏= (និ.ស.) អ្នកក៏ទៅខ្ញុំក៏ទៅ - សើចក៏ដោយយំក៏ដោយ ។

ករ= (ដៃ) - លើកករប្រណម្យ (លើកកំបង់អញ្ជលីសំពះ) ។

ករ - កករទឹក - កករប្រេង - កកូរទឹក កកូរសម្លកកូរ ។

កណ្ដុរ កកេរកការុងនៅក្បែរទ្វារ ។ បើគេកសាងកុដិ យើងក៏ត្រូវតែនាំគ្នាឃោស្នាកសាងព្រះវិហារមួយដែរ ហើយយើងទៅរកលោកទេពនិម្មិត ឲ្យលោកគូររូបទេពប្រណម្យមួយទៀត ។

## កល - កល់ - កលហ

កល= (ម.ថ.កល់) - មាយា - មានពុត - ល្បិច -

ចាយកល - ធ្វើកិច្ចកល - ចាញ់កលគេ . . .

កល់= (សើមពីក្រោមឲ្យខ្ពស់ហើយឲ្យស្មើមិនឲ្យល្អៀង) -

កល់ជើងតុឲ្យស្មើ - យកកំណល់ដែលកល់នេះចេញ . . .

កលហ ឬកលហ៍= (ម.ថ. កល់លៈហៈឬកល់) ជម្លោះ

កើតមានកលហនឹងគ្នា ... ។

កាលណាស្រុកកើតកលិយុគ បណ្ដាជនរមែងតែងបែកសាមគ្គី ពីគ្នា មានឧបាយកលផ្សេងៗ នាំឲ្យមានកលហ៍ពិរោធតែនឹងគ្នាឯង ខ្លះជឿណាស់ខាងមន្តអាគម ខំប្រឹងរៀបកំណល់គ្រូ ដាក់លើហ៊ឹងហើយ ថ្វាយបង្គំជាប្រក្រតី ដើម្បីឲ្យខ្លាំងពូកែមានជ័យជំនះ ។

## កា – កាណ៌ – ការ – ការណ៍

កា= កាខ្នងសំបុត្រ–កាទឹក (បំពង់សម្រាប់ដាក់ទឹក) ។

កាណ៌= ព្រះកាណ៌ (ត្រចៀកស្ដេច) ។

ការ= ធ្វើការ–ការពារ–ការងារ–ការសូត្រ ។

ការណ៍=(ហេតុ,ដំណើរ) ចាស់ការណ៍–មានការណ៍ក្រណាស់ ។

ខ្ញុំមានការណ៍ធំណាស់ ខ្ញុំបានសរសេរសំបុត្រកាខ្នងផ្ញើទៅសុំច្បាប់ ឈប់ធ្វើការបានប្រាំថ្ងៃ លុះការណ៍នោះបានសម្រេចហើយ ខ្ញុំនឹងវិល មកធ្វើការវិញ ។ ក្មួយស្រីខ្ញុំវាចេះការងារណាស់ វាការអម្បោះដាក់ខ្នារ យ៉ាងស្អាតហើយវាអន្ទងក្បាញធ្វើជាក្រមាគ្រប់ពណ៌ ។

## កេរ-កេរ្តិ៍ ឬ កិរ្តិ៍

កេរ = និយាយកេរគេ–បង់កេរគោះ (កេរក្លាយមកពីពាក្យកិរ្តិ៍) ។

កេរ្តិ៍ ឬ កិរ្តិ៍ = ស្រែកេរ្តិ៍របស់ខ្ញុំ – កេរ្តិ៍នេះបានមកពីជីដូនជីតា

ចែកឲ្យ ។ កូនអើយកេរ្តិ៍មេបា ចូលរក្សាគន់គិតគ្រង......

មាតាបិតាដែលទទួលមរណភាពទៅ តែងតែមានកេរ្តិ៍ទុកឲ្យកូនដូចជាស្រែចំការ គោក្របីជាដើម ហេតុនេះកូនត្រូវខំថែរក្សាកេរ្តិ៍ឲ្យគង់ល្អ បើមាតាបិតាទីទ័លក្រគ្មានរបស់អ្វីចែកឲ្យ ក៏កូនមិនត្រូវនិយាយសកេរអ្នកមានគុណដែរ ។

## កោដិ-កោដ្ឋ-កោត

កោដិ =(ម.ថ.កោត) - ១០លាន – ១កោដិ – ៩កោដិ

កោដ្ឋ = (ជង្រុក – របស់សំរាប់ដាក់សព – ធាតុ) – កោដ្ឋមាស – ហ៊ុនសុវណ្ណកោដ្ឋ (កោដ្ឋមាស) – ទិញកោដ្ឋប្រាក់ដាក់ធាតុ.....

កោត = (សៀនសៀប)–កោតក្រែង កោតខ្លាច .... ។

សេដ្ឋីនេះកំណាញ់ណាស់ គេពុំសូវកោតញញើតទេ មានសម្បត្តិកោដិឃ្លាំងពុំហ៊ានទិញកោដ្ឋមាសដាក់ធាតុមាតាបិតា ។ សុវណ្ណកោដ្ឋ គឺព្រះមរណនាមនៃព្រះបាទសម្ដេចព្រះនរោត្តម ។

## កុំ – កំ – កាំ – កម្ម

កុំ = (និ.ស.)–កុំទៅមក – កុំឲ្យ – កុំពោលពាក្យតាមកំហឹង ។

កំ = កំចាត់កំចាយ – កំណត់ – កំណើត – កំពង់ទឹក – កំពុងដេក – កំពុងបរិភោគអាហារ ។

កាំ = កាំជណ្ដើរ – កាំបិត – កាំរទេះ – កាំជ្រួច – កាំរន្ទះ – កាំភ្លើង – កាំភ្លោះ ។

កម្ម = (ម.ប.កាំ) ទទួលតាមកម្ម – រងកម្មវេទនា – មានកម្មពៀរនឹងគ្នា – កម្មករធ្វើការឥតស្រាកស្រាន្ត ។

ត្រូវកំចាត់កំចាយកំហឹងកុំចងពៀរក្រែងមានកម្មវេរាតទៅមុខ ។

កាំរន្ទះខ្លាំងត្បូងកែជាងគ្រាប់កាំភ្លើងទៅទៀត ។

# ខណ្ឌ – ខន្ធ – ខាន់ ឬ ខ័ន

ខណ្ឌ = ( សង្កាត់. បែក , កំណាត់ , កំរិត ) ខណ្ឌជញ្ជាំង – បោះគោល

ខណ្ឌព្រំបិការ – ស្លាយខណ្ឌស្ករ ឥតមានខណ្ឌទេ –

ព្រះរាជខណ្ឌ ។

ខន្ធ = (កងពួក, គំនរ, សេចក្ដីកំណត់) – ខន្ធ ៥ – ទំលាយខន្ធ

(ស្លាប់) រំលត់ខន្ធ (ចូលនិព្វាន) ។

ខាន់ ឬ ខ័ន = ព្រះខាន់រាជ្យ , កើតរោគខាន់បៀត ,

ខាន់លឿង , ខាន់ស្លាក់ , ខាន់ស្លា ។

ផ្ទះនេះគេបានចែកឲ្យកូនពីរនាក់ ខណ្ឌពាក់កណ្ដាលនឹងជញ្ជាំងក្ដារយ៉ាងសំខាន់ ។ រូបមនុស្សយើងមានខន្ធប្រាំ ព្រះខាន់រាជ្យដំកល់ទុកនៅព្រះបរមរាជវាំង ។ បុរសប្ដីប្រពន្ធនេះបានរៀបការអាពាហ៍ពិពាហ៍មានខាន់ស្លាពេញច្បាប់ ។ នៅខាងមុខប្រាសាទព្រះខាន់មានស្លាយខណ្ឌស្ករមួយដើម ។

មនុស្សនេះ កើតរោគខាន់លឿងយូរឆ្នាំណាស់មកហើយ នាំឲ្យខន្ធទាំងឡាយទ្រុឌទ្រោមទាំងអស់ ពេទ្យចំណានមានជំរិះសំខាន់យ៉ាងណាក៏មើលពុំជា ។

# ក នឹង ខ

អក្សរ ន្ន-ម្ម-ល្ល-ស្ស- ទាំង ៤ តួនេះផ្ញើជើងនឹងអក្សរ ក នឹង ខ មានដូចគ្នា ហេតុនេះត្រូវចំណាំ ដើម្បីកុំឲ្យច្រឡំរបៀបផ្ញើជើងនឹងអក្សរពីរតួខាងលើនេះ ៗ

ក្ន=ក្នក់ក្នាញ់-ក្នុង ...

ខ្ន=ខ្នល់ខ្នើយ-ដាក់ខ្នោះ-ខ្នាសកោសដូង ...

ក្ម=កូនក្មួយ-ម្ដាយក្មេក-ក្មេងក្មាង ...

ខ្ម=ខ្មងត្រី-វេញខ្មាញ់-ខ្មាសអៀន-ចិត្តខ្មាំង ...

ក្ល=ក្លាហាន-ក្លៀវក្លា-ក្លិនក្រអូប-ក្លើម្រាក់-ក្លែងក្លាយ ...

ខ្ល=ខ្លារខិន-ខ្លាចខ្លួន-ខ្លែងហើរ-ខ្លៅល្ងង់ខ្លះ ...

ក្ស=មហាក្សត្រិយ៍-ក្ស័យជីវិត-ក្សិណក្ស័យ-ក្សេមក្សាន្ត
ទឹកក្សីរ-ក្សត្រាធិការ ...

ខ្ស=ខ្សត់ខ្សោយ-ដីខ្សាច់-ខ្សឹកខ្សួលអួលព្រះទ័យ-ខ្សឹប
ខ្សាវ-ខ្សែក្រវាត់-ជក់ខ្សៀនាំគ្នាខ្សឹបខ្សៀវ ...

ម្ដាយក្មេកចូលទៅក្នុងផ្ទះ ហៅកូនស្រីឲ្យយកពូកខ្នល់ទៅឲ្យ

ទៅហាលថ្ងៃ ៗ ចូរកុំខ្ចាសអៀនទំនងការសិក្សា រៀនចិត្តក្លាហានវេលាមាន

អាសន្ន ៗ ក្មេងខ្ញុំបានធ្វើខ្លួនបង្កើតមួយថ្វាយព្រះមហាក្សត្រិយ៍ ៗ មនុស្ស

ខ្សត់ខ្សោយពុំសូវបានសុខក្រមក្មួនប៉ុន្មានទេ ៗ

---

## ពាក្យទំនឹមទំនៀមបុរាណ

– បេះមកពីរៀន មានមកពីរក ៗ

– តក់ ៗ ពេញបំពង់ ៗ

– សន្សំមកុំបំពោល ក្រែងពុំដល់ដូចប្រាថ្នា ៗ

– រត់ឥតអំពើ ដើរអំណត់បំរើនជាង ៗ

– បើខឹងឲ្យខំអត់ បើខ្សត់ឲ្យខំរក ៗ

– ងើយរាស្ត្រ ទុនរាជាក់គ្រាប់ ៗ

– បង់ពិសាឲ្យរកអន្ទក់ បង់ស្រណុកឲ្យនៀយពីក្មេង ៗ

– ត្រកៗអ្នកស្រុកមើលងាយ រលាស់គូថខ្ចាយមានទុតមានការ ៗ

– ដូនមួយថ្ងាយមានតក់មាននាឡិ ៗ

– សំដីជាឯក លេខជាទោ អក្សរជាត្រី ៗ

– ស៊ីព្រោះលោះកម្លាំង ៗ

- មនុស្សគេយកសំដី ដំរីគេយកភ្លុក ។
- សាច់មិនបានស៊ីយកឆ្អឹងព្យួរក ។
- ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឲ្យយក ។
- អាគមផ្សំអាយុ ។
- ក្អួតទៅហោរ ហោរទៅជាង ។
- បេះដប់ពុំស្មើនឹងប្រសប់មួយ ។
- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ។
- សីលជាស្ពាន ទានជាស្បៀង ។
- រពឹសដៃ ផ្ទៃផ្អែត ។
- កាប់បំពង់រង់ទឹកភ្លៀង ។
- កុំបោះសន្ទូចបំលងភ្នំ ។

## គ – គរ – គភ ឬ គភ៌

គ = មនុស្សគ – ប្រាក់គ (ឥតសូរ) ។

គរ = ដើមគរ – សម្ដីគរ = យកគរញាត់ខ្នើយ – គរឲ្យខ្ពស់ធ្វើជាគំនរ – ប្រាក់មានគរគោក...

គភ៌= (ម. ថ. គ័រ) ស្រីមានគភ៌-ទ្រង់គភ៌ ។

ខ្ញុំឃើញស្រីម្នាក់មានគភ៌ផង ដើររើសផ្លែតរទុំតាមមាត់អូរគរ ។

## គន់-គុណ-គុន

គន់= គន់មើល - គយគន់ - គន់គូរ - បង្គន់ ឬ ប៉ាំងគន់....

គុណ= លេខគុណ - គុណធម៌ - គុណមាតាបិតា - គុណនាម....

គុន= ហាត់គុនឲ្យស្ទាត់ - គុនដាវ - គុនដំបង.....

មានគ្រូម្នាក់ចេះគុនដាវ គុនដំបង ហើយចេះទាំងគន់គូរមើលគូព្រេងទៀតផង គ្រូនេះមានគុណលើគេស្ទើរតែគ្រប់គ្នា ។

## គូ - គូរ

គូ= ន. ស្នាមភ្លោះព័ទ្ធជុំវិញបន្ទាយ ឬ វាំង ។ ទៅមុជទឹកគូ....

គូ= ន. ចំនួនពីរផ្ទឹមគ្នា - មួយគូ - ព្រាបមួយគូ - គូកម្ម....

គូរ= កិ. ធ្វើឲ្យកើតជាគំនូរដំណាងរូបរាង សរពើ - គូររូប - គូរគំនូរ

កាលពីថ្ងៃអាទិត្យមុនខ្ញុំបានទៅមុជទឹកគូ ឃើញតាចាស់

ម្នាក់កំពុងតែគន់គូរគូព្រេងឲ្យនាងក្រមុំម្នាក់អង្គុយនៅមាត់គូ ហើយតាទាយថាគូស្រករនាងឯងជិតដល់ហើយ ។

## គំ – គុម្ព – គុម ឬ គុំ

គំ= គំនាប់ - គំនិត - គំនូរ - គំនូសគូស - គំនុំ - គំពមគំពោះ...

គុម្ព= គុម្ពឈើ - គុម្ពឫស្សី - គុម្ពោត - ស្លឹកគ្រៃមួយគុម្ព...

គុម ឬ គុំ= គុំគួន - គុំព្យាបាទ - គុំបំផ្លាញ... ។

មនុស្សគ ឈរក្រោមដើមគរ ក្បែរគំនរអុស ។ គ្រូនេះបេះគន់គូរមើលពសីបូកផ្សំថ្ងៃខគុណលេខរហ័សណាស់ ។ បុរសនោះមានគំនិតអាក្រក់គុំព្យាបាទគេ កាន់កាំបិតទៅពួនសម្ងំនៅប្របគុម្ពឫស្សី ។

## កៀប – គាប

កៀប= រិតដោយដង្កៀប, ក្តាមកៀបដៃ....

គាប= រិតដោយឃ្នាប ឬ គំនាប - គាបត្នោត - គាបមនុស្ស...

ប្អូនកុំលេងនឹងសត្វណាដែលមានដង្កៀបខ្លាចក្រែងវាកៀបដៃ ។

គេយកឃ្នាបគាបចោរសួរយកចម្លើយ ដួនកាលគេយកដំបៀតតៀតត្រចៀកឬកៀបសាច់ក៏សឹងមាន ។

## ក្រ-គ្រ

អ្នកសរសេរច្រើនច្រឡំពាក្យដែលចេញពី „ក្រ នឹង គ្រ„ ពីព្រោះធ្លាប់និយាយខុសខ្យល់អក្សរតាំងពីដើមមក លុះសរសេរក៏សរសេរតាមសព្ទដែលនិយាយនោះ ។

ក្រ= ក្របសៀវភៅ-ក្រាសសិតសក់-ក្រាស់ស្តើង-ក្រិត្យក្រម-ក្រុបទ្វារ-សត្វក្រួប-មុខក្រៀមក្រោះ-ក្រេវក្រោធ-ក្រោលក្របី...

គ្រ= គ្របពាន-គ្រាប់ឈើ-គ្រោះថ្នាក់-ស្ទឹកគ្រៃ...។

ត្រូវយកក្រដាសក្រាស់ធ្វើក្របសៀវភៅការពារកុំឲ្យឆាប់រហែក ។ កាលណាសិតសក់រួចហើយ ត្រូវទុកដាក់ក្រាសទនឹងស្នូតក្នុងប្រអប់គ្របឲ្យជិតកុំឲ្យធូលីចូលបាន ។ បងខ្ញុំមានគ្រោះថ្នាក់ក្រាស់ក្រៃ អាចោរចង្រៃវាចូលលួចក្របីអស់ពីក្នុងក្រោល គាត់ក្រេវក្រោធកើតទុក្ខមុខក្រៀមក្រោះ ។

## ង - ងរ - ងា - ងារ

ង =ទូកង - ពត់ឈើឲ្យងបុង - ក្អែកងងឹត - ងងុយដេក.....

ងរ = (សំដែងអាការមាយា ) នាំងរ ស្រីងរច្រើន...

ងា = ងាដៃងាជើង - ងាដៃជន្ទលេង...

ងារ = ( មុខងារ ) ការងារ - ងារមន្ត្រី ដីមួយងារ - ស្នងងារ... ។

អ្នកអង្គុយលើក្បាលទូកង ងាដៃទៅមុខទៅក្រោយ ខ្លះប៉ិនប្រសប់ បានងារការក្នុងរបៀបអុំប្តែវទូកនោះផង ។ ស្រីនេះចិត្តសាវា ងរចុះងរឡើង ស្នងងារឲ្យគេពល់តែឆ្នាំ ។

## ប - បរ

ប = ឆ្នាំប (ខ្កែ) បឈើ ( ពុះឈើ )....

បរ = បររទេះទៅ - បរយាត្រា - បរបានឹងគ្នា - បរណៃ......

កាលពីឆ្នាំប ព្រះមហាក្សត្រិយ៍ទ្រង់បានបរលើណាទៅកាន់ប្រទេស លាវ ដើម្បីបរបាការណ៍សុខទុក្ខកងព្រះនគរ ។

## ហារ-ហារ៌ុ-អាហារ-អាហារ្យ

ហារ= ហារសាស្ត្រ ដើមហារផ្កាក្រហម សុភាហារបុរស ធ្វើចំណាំរហាររបង ....

ហារ៌ុ= (ម.ថ.ហ) ហារ៌ុមាស ហារ៌ុប្រាក់ បុរាណពប់គានហារ៌ុ....

អាហារ= មានអាហារល្អ (បុគ្គល – មារយាទ – ចរិយា)

អាហារ្យ= អាហារ្យវត្ត – អាហារ្យយោគី ....

គេហារសាស្ត្រទីងដៃគហារ ៗ អ្នកចំការហាររបងព័ទ្ធជុំវិញសួនច្បារ ៗ នារីនេះពាក់ហារ៌ុមាស មានអាហាររម្យទម ៗ លោកសុភាហារបុរសបានកោះហៅអាហារ្យយោគី អំពីបភ័យអ្នកស្រុកឲ្យយកតែអុសហារបូជាខ្មោច ៗ

## បិត-បិត្ត-ពិបិត្រ ឬ វិបិត្រ

បិត= បិតខ្មៅដៃ–បិតក្របក–បិតទីងកាំបិតមុត

បិត្ត= បិត្តល្អ បិត្តមានអារម្មណ៍ បិត្តឃោរឃៅ ....

ពិបិត្រ ឬ វិបិត្រ= ដែលរំលេចឬភ្លាស់ក្បាច់ចេនាឬល្អប្លែក)

ក្បាច់វិចិត្រ – ខំវិចិត្រឲ្យល្អប្លែក...។

កុមារនេះ ខំយកចិត្តទុកដាក់នឹងការសូត្ររៀនណាស់ ដល់ពេល គ្រូគំនូរវាយកខ្មៅដៃដែលចិតទុកយ៉ាងស្រួចមកគូរឲ្យល្អវិចិត្រ ។

## ហោត–ហោទ

ហោត= ប្រាំងហោត – ដីហោត – បំណោតគំ...

ហោទ= សួរហោទ - សេចក្ដីហោទ - ដោះបំណោទដែលគេហោទ..

មានអ្នកប្រាជ្ញម្នាក់សួរហោទថា ពីព្រោះអ្វីបានជាប្រាំងទន្លេមាន កន្លែងខ្លះហោតចុះទៅកំពង់ពុំបាន កន្លែងខ្លះទេរចុះឡើងបានដោយងាយ ចូរដោះស្រាយបំណោទនេះឲ្យបានពិស្ដារ ។

## ប្រាង–ប្រាំង–ជ្រាំង

ប្រាង= បន្ទាប្រាង–សម្រាស់ឬស្សីច្រើនប្រាង...

ប្រាំង= ប្រាំងទន្លេ – ប្រាំងសមុទ្រ – ប្រាំងហោត – ប្រាំងទេរ

ជ្រាំង = កើតជ្រាំងពេញមាត់ - ជ្រាំងខ្ទុរសម្ង... ។

តាមច្រាំងទន្លេ អ្នកនេសាទត្រីដោតសម្រាស់ប្រូងប្រាង ។ ទារកនេះ

កើតជ្រាំងពេញអណ្ដាតសក្បុសដូចដីឥដ្ឋនៅមាត់ច្រាំងទន្លេកំពង់ឆ្នាំង ។

## ឆ្មា - ឆ្មារ

ឆ្មា = ឆ្មាស្រុក - ឆ្មាបា - ឆ្មាជាសត្វចតុប្បាទសត្រូវនឹងកណ្ដុរ... ។

ឆ្មារ = ខ្សែឆ្មារ - សរសៃអម្បោះឆ្មារ - ក្រូបឆ្មារ... ។

ឆ្មាជាសត្វចតុប្បាទចាប់កណ្ដុរបរិភោគជាអាហារ ពោមព័ឆ្មារ ទន់ដូចសម្លីកប្បាស ។

## ឆ្លាត - ឈ្លាស - ឆ្លៀត - ឈ្លៀស

ឆ្លាតឬឈ្លាស - គុ. (ប៉ិនប្រសប់-ស្ទាត់) ប្រាជ្ញាឆ្លាតឬឈ្លាស-មនុស្សឈ្លាសឬឆ្លាត - ឈ្លាសវៃ...

ឆ្លៀត - កិ. (រំលែកពេលឬល្អួចបេក់ធ្វើកិច្ចការអ្វីៗ) ឆ្លៀតធ្វើការផ្សេងទៀតផង - ធ្វើការរាជការផង ឆ្លៀតធ្វើជំនួញផង ។

ឈ្លៀស– កិ. ( ស្ទាត់កេណ្ឌយកមនុស្សឬសត្វមកប្រើជាពលការ
បណ្តើរសិន ) ឈ្លៀសមនុស្ស ( ស្ទាត់កេណ្ឌមនុស្ស )
ឈ្លៀសគោរទេះ...

មានមេឃុំម្នាក់វ័យនៅក្មេង ធ្វើការពលការឆ្លាតវៃណាស់ ហើយ
ទៀតធ្វើការងារបំពេញមជីវិតខ្លួនឯងផង បើមានការធ្វើបុណ្យក្នុងភូមិម្តងៗ
ដោយប្រញឹកប្រញាប់ មេឃុំឈ្លៀសអ្នកស្រុកឲ្យលើកថ្នល់ភ្លាម ៗ

**ឆ្វេង – ឈ្វេង**

ឆ្វេង = ន. (ទីទៃពីស្តាំ) ខាងឆ្វេងដៃ មនុស្សឆ្វេង (មនុស្ស
ធ្វើការអ្វីៗមិនចុះបែប)

ឈ្វេង = គុ. (ថ្លាជ្រះឥតមន្ទិល) ទឹកថ្លាឈ្វេង... ។
កិ. ឈ្វេងយល់ (រំពឹងគិតយល់ដោយប្រាជ្ញាដ៏ថ្លា) ។

មនុស្សមានប្រាជ្ញាឆាប់ឈ្វេងយល់ការណាស់ បើមានការណ៍អ្វី
កត្រូវរំពឹងគិតដោយហ្មត់ចត់ទើបបានធ្វើ មិនធ្វើបំពាក់បំពានខុស
បែបបទដូចមនុស្សឆ្វេងនោះឡើយ ។

## ជរ – ជូរ – ជួ – ជួរ

ជរ= ហូលជរ–ជរជាយ–សំពត់មានជរ

ជូរ= អម្ពិលជូរ–សម្លម្ជូរ....

ជួ= មនុស្សជួ–ជួជង–អាក្រក់ជួជាតិ....

ជួរ= ឈរជាជួរ-ជួរពោត–ជួរដំបូរ... ។

សម្លណាមានរសជាតិជូរ ហៅថាសម្លម្ជូរ ។ ឪពុកក្មេកឃើញកូនប្រសាស្លៀកហូលជរដើរលេង ឥតមានគួរសមទឹងញាតិសន្តាន ក៏ត្មះតិះដៀលថា អានេះជួជងណាស់ ប្រហែលជាគាត់ទៅជួរខាងម្តាយវា ។

## ជុំ – ជំ – ជាំ

ជុំ= ដើរមួយជុំ – ប្រទក្សិណប៉ានាបីជុំ – ទីប្រជុំ...

ជំ= ជំទាវ – ជំនន់ – ជំនួញ – ជំនុំជំរះ – សំពត់ជំនិ...

ជាំ= មុខជាំ – ក្រហមជាំ – ដីជោកជាំទឹក... ។

វេលានោះ គេប្រជុំគ្នានៅសាលាស្រុក លុះរាស្ត្របានមកជួបជុំគ្នា

ហើយទើបគេដំនុំគ្នាពីផ្លូវដំនួញផ្សេងៗ ។ ទៅក្រុមដំនុំដំណើររឿងដំទប់ដុំ ដែលគេកាយដាំមុខ ។

## ញុះ - ញោស - ញោះ

ញុះ= ញុះញង់ - ញុះញុយៗ...

ញោស= ស្វាយទុំញោស - ចាស់ញោស - ស្ពឺដេរ

បន្ទោសញោសពេកណាស់...

ញោះ= ញោះមួយដំបង - ញោះមួយម៉ាត់ប្រឡោតតួង... ។

កុំញុះញង់គេឲ្យឈ្លោះគ្នា កំហឹងដ៏ជ្រុលញោសពេកនាំឲ្យមានទុក្ខធំ ។ មនុស្សចិត្តស្រាល បើគេញោះតែមួយម៉ាត់ខឹងប្រលោតមួយរំពេច ។

---

## ពាក្យទំនីមទំនៀមបុរាណ

- គេខុសកុំអាលអរ គេសាទរកុំអាលអួត
- ដានមិនកើតទៅបន្ទោសដែក
- នៅស្រុកឲ្យស្រួសបន្ទា អារសាច់ដូនខ្លាទើបនៅស្រុកបាន
- ផ្គរខាំឲ្យគេមួស់ គោផ្គរខ្ញែងឲ្យគេនាយ

- នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយជាមួយ
- ស្អប់កុំឲ្យផាញ់ ស្រឡាញ់កុំឲ្យខ្ចី
- ទឹកជោរត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី
- គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ
- រហ័សតែមាត់ ត្រគាកស្ទាប់ស្ដូក
- ឮផ្គរកុំអាលចាក់ទឹកចោល
- កុំយកមេឃព្រាប់អង្គុយ
- បើមិនជួយចូកជួយចែវ កុំយកជើងរាទឹក
- ញ្ញៅនៅថ្ពក់ ទំពក់នៅដៃ
- គោកៗសឹកតែមាត់ត្រដោក ផ្អែតតែពោះក្របី
- ឈើកោងវល្លិ៍ព័ទ្ធ មនុស្សសោតព្រាតកុំយកជាគ្នា
- គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ
- ក្អែកមួយជាក្អែកដប់
- ទូកបែកជាទូកគត់ ទូកកំបុតជាទូកង
- ទូកទៅ កំពង់នៅ
- ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន
- ឃ្លោកលិច អំបែងអណ្ដែត

## ជ័យ – ជ៏យ – ជ័រ

ជ័យ = ទូកជ័យ កំពង់ជ័យ-ធ្វូនជ័យ

ជ៏យ = ទិ. ទ្រព្យដ៏ប្រសើរ – គុណដ៏ឧត្តម – ធម៌ដ៏បវរ

ជ័រ = បូសជ័រ – ដាំបៅជ័រ រកស៊ីទាំងត្រជ័រ ។

ពាណិជនេះមានធនធានដ៏ប្រសើរ បានជិះទូកជ័យទៅស្រុកគាត់ ត្រូវខ្យល់ព្យុះបោកលិចទូក ខំប្រឹងត្រដរហែលទាល់តែដល់ត្រើយ ។

## ជុស – ជុះ – ខុស

ជុស = ជុសក្អែល – ជុសលាន ជុសខាត់ – ជុសធ្មេញនឹងច្រាស់...

ជុះ = ស្រូវជុះពន្លក – ដីជុះខ្ពស់ – រកស៊ីជុះជាល....

ខុស = សរសេរខុស – ធ្វើលេខខុស – សេចក្ដីខុស ។

ខុសហើយឯង ហេតុអ្វីបានជាយកគោទៅចងឲ្យត្រដុសគ្នាលើ ដំណាំកំពុងតែដុះល្អខូចខ្ទីអស់ ។

## ត នឹង ប

ចូរប្រយ័ត្នជើងជើងអក្សរ «ប្ប-ល្ល» នឹងតួអក្សរ «ត-ថ» ។

ជើង «ប្ប» ត្រូវនៅក្រោម «ត» មិនត្រូវនៅក្រោម «ថ» ទេ៖

ត្បាញ – ត្បាត្រចៀក – ត្បាល់កិន – ត្បុតត្រី – ត្បូលបូលខាន់ត្បូង – ត្បូងខៀវ – ម្ចាស់ជីវិតលើត្បូង – ត្បូងពេជ្រ...

ជើង «ល្ល» ផ្ទើនឹងតួអក្សរ «ត» មានពាក្យតិចណាស់ ដូចជា៖ ...ករបាំ – ផលត្លឹងត្លៀវផុតព្រៃ ក្របត្លុងមួលត្លុំ ។ ក្រៅពីនេះជើង «ល្ល» ផ្ទើនឹងតួ «ថ» ទាំងអស់៖ ថ្លស់ថ្លោយ – ទឹកថ្លា – ថ្លាំងធំ – ថ្លឹងមាស – ...កត្រពាំង – ថ្លៃថ្នូរ – កូនថ្លោស – ថ្លោសបិត្ត...

អក្សរ «អ» ត្រូវនៅក្រោម «ត»៖ វង់ត្អង, ត្អូញត្អែរ, កូនក្មេងត្អើក

## ប៉ោះ – បំណោះ – ត្រិះ – ពិរិះ – ជិរិះ

ប៉ោះ = បំណោះ មនុស្សប៉ោះ, កុមារនេះមានបំណោះគ្រាន់បើ ...

ត្រិះ – ពិរិះ – ជិរិះ = ទ្រង់ត្រិះរិះ, ទ្រង់ព្រះជិរិះ, (ទ្រង់គិត) លោកមានជិរិះល្អ (មានសេចក្តីរិះគិតត្រូវ)...

មនុស្សណាមិនចេះអក្សរគេទុកដូចជាមនុស្សខ្វាក់ ៗ ត្រូវខំត្រ...
ស្វែងរកចំណេះវិជ្ជាទាន់វ័យនៅក្មេង . . .

## ត្រៀប - ទ្រាប

ត្រៀប= កិ.វិ. ដែលដេរជាសដោយមានរបៀប ៗ ឈរត្រៀ...
មើលទៅឃើញត្រៀប - មនុស្សឈរត្រៀបត្រា . . .

ទ្រាប= ន. ឬកិ. ទ្រាបបាយផ្អែម ទ្រាបល្វ ៗ ទ្រាបស...
ពីលើ - ទ្រាបលើស្មា ៗ

មានគេធ្វើបុណ្យត្រៀបត្រាក្នុងវត្ត មានសិស្សលោកម្នាក់ដើរ...
គេដួលទ្រាបលើសម្ទឹងទ្រាបបាយដែលគេប្រគេនលោកកំពប់អស់

## ថ្មារ - ថ្មើរ

ថ្មារ= ពេល កាល សព្វថ្ងៃច្រើនប្រើ "ថ្មើរ" វិញ ថ្មើរម៉ានហើ...
យប់ថ្មើរណោះហើយទៅពុំបានទេ

ថ្មើរ= ថ្មើរជើង ទាហានថ្មើរជើង ( ពលដើរដោយជើ...
ថ្មើរព្រៃបរបាញ់សត្វក្នុងព្រឹក្សា . . . ៗ

មកដល់ទីនេះថ្មើរម៉ោន  អ្នកឃើញពលថ្មើរជើងមកហើយឬនៅ ។

**ទ - ទរ - ទា - ទារ**

ទ= ទត្រងទឹកភ្លៀង, ទឹកហូរតាមទស័ង្កសី....

ទរ= (ជេរស្តីបន្ទោស) កូនសិស្សខ្ជិលគ្រូទរសន្ធឹក...

ទា= សត្វទាឈ្មោលញី, ទាញីទទះស្លាបហែលទឹក

ទារ= ទារប្រាក់ថ្លៃផ្ទះ, ទារប្រាក់ថ្លៃទា, ជំទប់តឹងទារប្រាក់ ពន្ធថ្លៃដី ។

ប្តីទរប្រពន្ធសន្ធឹក  ពីព្រោះស្តោះទឹកមាត់ទៅលើទត្រងទឹក ។

ព្រឹកស្អែកខ្ញុំទៅទារប្រាក់ថ្លៃទាអំពីជង្ខៅទា ។

**ទាន - ទៀន**

ទាន= ធ្វើទាន - ឲ្យទានបាយសម្ល - សូមទានមេត្តាប្រោស...

ទៀន= ទៀនធូប - អុជទៀនជ័យ - លក់ទៀនវស្សា.....

លោកតាគាត់ទៅសមាទានសីលឯវត្ត  ដៃកាន់ជើងពានមានផ្កាទឹង ទៀនធូប ។

## ទល់-ទោស-ទោះ

ទល់= (រាំងទប់) ទប់ឆ្នុស់ក្នុងព្រែក ទល់ទប់ឲ្យជាប់......

ទោស= ទោសធ្ងន់ - កាត់ទោសសម្លាប់ - ទោសពៃរ៍ - សូមអភ័យទោស......

ទោះ= ទោះល្អក្តីអាក្រក់ក្តី - ទោះបីខុសត្រូវដូចម្តេច......ៗ

ជនល្មើសត្រូវមានទោសពិន័យជាប្រាក់មួយពាន់រៀល អំពីប្រព្រឹត្តខុសទំនងបញ្ញត្តិ ៗ សេចក្តីនេះទោះបីលើសលស់ឆ្គាំឆ្គងយ៉ាងណា សូមមេត្តាអភ័យទោស ៗ

## ទាប-ទៀប

ទាប= ដីទាប - ពងទាបទ្រនាប់ - កិរិយាពបទាប....

ទៀប= ទៀបនឹងដល់ - ទៀបភ្លឺ - ទៀបកោះ - ផ្លែទៀបទុំ - ទៀបដាក់ចំណីអាហារ.... ៗ

កុមារីនេះមានកិរិយាសុភាពរាបទាបគួរសមណាស់ បានផ្លែទៀបទុំ ដាក់កន្ត្រទៀបសរិទ្ធិកណ្តៀតយកទៅជូនអ្នកគ្រូបង្រៀន ។

| ទ្រព្យ – ទ្រាប់ – ត្រប់ |
|---|

ទ្រព្យ = ន. វត្ថុ–ធនធាន–សម្បត្តិ ។ ថែទាំទើបគង់ទ្រព្យ ។

ទ្រាប់ = កិ.–រង–កលពីក្រោម ។ ទ្រាប់ធ្វើជាទ្រនាប់......

ត្រប់ = ន.–ឈ្មោះដំណាំមានផ្លែបរិភោគជាបន្លែឬអន្លក់

ត្រប់ពុតលំញង – ត្រប់ក្រាមរមាស....... ។

យាយត្រប់គាត់មានទ្រព្យសម្បត្តិច្រើន គាត់យកស្លឹកចេកទ្រាប់បាតកញ្ជើដាក់ផ្លែត្រប់ពេញ ទូលទៅលក់ឯផ្សារ ហើយគាត់ទិញបានត្រីកន្ត្រប់មួយគូ ។

| ធង – ធង់ – ធុង |
|---|

ធង = ម.ថ. ធន់– ទ្រព្យសម្បត្តិ–ធនធាន–ទ្រព្យធន

(កុំសរសេរយ៉ាងនេះ៖ ធន់ធាន).....

ធន់ = (ទ្រាំ, អត់, ធ្មត់, ស៊ូ) ធន់ជម្ងឺ – ធន់រងា...

ធុន = (បែបយ៉ាង, កំណើតដូចគ្នា) បានមួយធុន – កែវមួយធុន – មនុស្សមួយធុន... ។

ពាណិជម្នាក់មានទ្រព្យធនធានច្រើនណាស់ ប្រឹងធ្វើការមិនដឹងយប់-ថ្ងៃ ធន់ក្ដៅធន់ត្រជាក់ មនុស្សធុននេះ ពុំសូវមានច្រើនទេ ។

| ធុំ – ធំ |
| --- |

ធុំ = (ក្លិន) – ធុំក្រអូប – ធុំអាក្រក់ – ធុំក្លិនសាយ...

ធំ = (ទីទៃពីតូច) ផ្ទះធំទូលាយ – សាលាធំ – ឪពុកធំ – ធំប្រុសធំស្រី ។

កាលប្អូនខ្ញុំនៅតូចវាស្ដើកគ្រោកណាស់ ខោអាវវាកខ្វក់ធុំក្លិនអសោចិ៍ លុះដល់វាធំឡើង ចូលទៅរៀនឯសាលាវាស្អាតជានិច្ច

| ទប់ – ទព្វ |
| --- |

ទប់ = ស្ទែងនប់ – លើកទំនប់ទប់ទឹក...

នព្វ = (ប្រាំបួន – មាសនព្វគុណ (មាសទឹក៩) – នព្វគ្រោះ (ឈ្មោះផ្កាយគ្រោះ៩) នព្វន្ត (វិជ្ជាលេខមាន៩) លេខនព្វន្ត – ក្បួននព្វន្ត.... ។

មានអ្នកស្រែម្នាក់កំពុងតែលើកទំនប់ទប់ទឹក ឃើញកុមារម្នាក់ដើរ កជិតក៏សួរថា នាងឯងចេះក្បួននព្វន្តឬទេ បើចេះចូររកថ្ងៃស្ទូងនប់១៥ ត្រូវជាប៉ុន្មានរៀល បើស្ទូង ២ ថ្ងៃ ២៤រៀល ។

## នូវ – នៅ

នូវ = (ម.ថ.នៅ) និ. នឹងហើយនឹង: មាតាបិតានឹងបងប្អូននូវមាមីង ទាំងអស់ ។

សា.និ. (ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើ) នឹងបាននូវផល ល្អ–អ្នកនឹងសម្រេចនូវវិជ្ជាដ៏ប្រសើរ សិស្សប្រព្រឹត្តនូវអំពើល្អ... ។

នៅ = កិ. នៅផ្ទះនៅក្នុងបន្ទប់ – អស់ហើយឬនៅ – នៅឡើយ ។ សិស្សទាំងឡាយ ចូរអ្នកខំប្រឹងសូត្ររៀន ឲ្យបានសម្រេច នូវចំណេះវិជ្ជា ដ៏ប្រសើរទាន់ខ្លួនអ្នកនៅក្មេង ។

## បា – បារ – បិត – បិទ

បា = នៃបា – ហៃបា – មេបា – គោបា – ក្របីបា...

បារ = បារដីកង្ធរណ្ដៅ – ក្មេងបារយំយប់..,

បិត = បិតផ្ដៅ – បិតឈើស្រួច – បិតស្រា...

បិទ = បិទទ្វារ – បិទមាស – បិទមុខ បិទបាំង ។

ឪពុកចៅប៉ាំមានគោបាមួយធំ ខ្លួនធំបារ យកទៅលក់ឲ្យចិនបិតស្រា នៅទន្លេបិទជិតផ្សារកំពង់ចាម ។

## បូ – បូរ – បូព៌

បូ = ចងបូ – សក់ចងបូ...

បូរ = បូរបាច់ – និយាយបូរបាច់ប្រាប់គេ...

បូព៌ = ទិសបូព៌ ឬទិសបូព៌ា (ទិសខាងកើត)

កាលពីថ្ងៃអាទិត្យ មានកុមារីម្នាក់ដើរមកពីទិសបូព៌ ចងបូសក់យ៉ាងស្រស់ មុខរីករាយហើយឈប់និយាយបូរបាច់នឹងនារីម្នាក់នៅក្បែរផ្សារត្រី ។

## បាត - បាត្រ - បាទ

បាត =( ប៉ែកខាងក្រោមនៃដំរៅផ្ទៃដៃ - ជើង ) បាតដៃ

បាតបឹង - បាតខ្ទះ - ឫសដូងបាត - បិណ្ឌបាត...

បាត្រ = (ភាជនៈ) = បាត្រលោក - បាត្រដែក - ស្ពាកបាត្រ

បាទ (ជើង) - ព្រះបាទ - ប្រាក់បាទ - ក្រាបទៀបព្រះ

បាទា - សត្វចតុប្បាទ...

ប ជើង ដ មានពាក្យតែ ៤ ម៉ាត់ = ប្ដី - ប្ដឹង - ប្ដូរ - ប្ដេជ្ញា ។

ម្ដាយខ្ញុំបាទគាត់បានផ្ញើប្រាក់ទៅទិញបាត្រមួយ នៅស្រុកសៀមថ្លៃម្ភៃបាទ ពងឈើ បាតរាបស្មើដូចជាបាតខ្ទះ ទុកប្រគេនលោកបងខ្ញុំដាក់បង្អាន់បិណ្ឌបាត ។

## បំរាស - បំរាស់ - បំរះ

បំរាស ឬ បម្រាស = កិ. ធ្វើឲ្យប្រាស ឲ្យឃ្លាតចេញ

ប្រាសប្រាត់....

បំរាស់ ឬ បម្រាស់ ពាក្យសម្រាប់និយាយផ្សំនឹងពាក្យបំរើ

បំរើបំរាស់ គឺទទួលការៈតាមកិច្ចដែលគេប្រើប្រាស់....។

បំរះ ឬ បម្រះ ឬ បង្រះ = បំរះខ្លួន – ប្រះប្រាណខ្លួន ទៅមករឿយ ៗ ៗ

កុមារនេះខំបំរើបំរាស់មាតាណាស់ លុះដល់មាតាប្រាសព្រាត់ចោល ទៅក៏យំប្រះប្រាណខ្លួន សោកស្ដាយមាតាឥតមានល្ហែឡើយ

## បះ-ប៉ះ-បាស

បះ = ក្ដារបះចុងម្ខាង – បះបោរនឹងទទឹង – នាំគ្នាបះឈប់ធ្វើការ

ប៉ះ – ប៉ះទង្គិច – ប៉ះសំពត់ក្លាប់ – ទឹមគោប៉ះគ្នា – ប៉ះមុខគ្នា – ប៉ះពារ – ប៉ះពាល់...

បាស =(អម្បោះចងសំពត់ស្នប) - ខ្សែបាស - បន្ទុស្ទឹកបាស

«បាស់ សរសេរដូចនេះគ្មានទេ» ។

ថ្ងៃមួយ នៅស្រុកមាខ្ញុំ មានមនុស្សបះបោរផ្អើលឆោឡោរត់ប៉ះទង្គិចគ្នា ខ្លះភ័យរត់បុះទឹក ខ្លះរត់ទៅពួនសម្ងំក្នុងកន្ទ្របវល្លិបាស ។

## បង្កាន់ - ប្រកាន់

បង្កាន់ដៃ = ន. បង្កាន់ដៃស្ពាន - សំបុត្របង្កាន់ដៃ...

ប្រកាន់ = កិ. ប្រកាន់ទោស - ប្រកាន់ពួកបក្ខ... ។

កាលពីថ្ងៃមុន ខ្ញុំបាទបានបង់ពន្ធអាកររួចហើយ មានទាំងបង្កាន់ដៃសំគាល់ទៀតផង ឥឡូវនេះមានគេមកប្រកាន់ថាខ្ញុំបាទពុំទាន់បង់ពន្ធនោះទេ ។

## បញ្ញត្ត - ប្រព្រឹត្ត - បញ្ញត្តិ - ប្រព្រឹត្តិ

បញ្ញត្ត - ប្រព្រឹត្ត = (កិ. គុ.) រាជការបញ្ញត្ត - ប្រព្រឹត្តទុច្ចរិត - មានច្បាប់បញ្ញត្ត - សិស្សប្រព្រឹត្តសុចរិតត្រឹមត្រូវ...

បញ្ញត្តិ - ប្រព្រឹត្តិ = (ន.) មានបញ្ញត្តិ - ការប្រព្រឹត្តិ - ខុសនឹងបញ្ញត្តិ - សេចក្ដីប្រព្រឹត្តិ - ត្រូវធ្វើតាមបញ្ញត្តិ...

សិស្សល្អ ប្រព្រឹត្តសុចរិតតាមបញ្ញត្តិ ។ មានព្រះរាជប្រកាសបញ្ញត្តដល់មនុស្សទុច្ចរិតឲ្យខំប្រព្រឹត្តត្រឹមត្រូវ ។ ការប្រព្រឹត្តិល្អឥតមានខុសនឹងបញ្ញត្តិ នាំឲ្យបានសុខគ្រប់ប្រការ ។

" ចូរចំណាំពាក្យពីរម៉ាត់ខាងលើនេះ បើជាកិរិយា ឬគុណនាមត្រូវសរសេរ "ត្ត" បញ្ញត្ត, ប្រព្រឹត្ត បើជានាមវិញ ត្រូវសរសេរ "ត្តិ" បញ្ញត្តិ ប្រព្រឹត្តិ

## ប្រណិប័តន៍ - បដិបត្តិ ឬ ប្រតិបត្តិ

ប្រណិប័តន៍ = ន. (ការសំដែងសេចក្ដីគោរព - ការគំនាប់ ឬសំពះ) សូមក្រាបប្រណិប័តន៍ ចូលមកលោក...

បដិបត្តិ ឬ ប្រតិបត្តិ = (ម.សំ.) (ការប្រព្រឹត្ត - កាន់ - ធ្វើតាម) សេចក្ដីបដិបត្តិ - ត្រូវប្រតិបត្តិតាមច្បាប់ ។

អ្នកត្រូវប្រណិប័តន៍ចាស់ព្រឹទ្ធាចារ្យវេលាអ្នកជួបប្រទះតាមផ្លូវ ។ នៅសាលារៀនត្រូវគោរពប្រតិបត្តិគ្រូកុំបីឲ្យខ្វះ ។ បើរៀនធម៌រៀនច្បាប់ ត្រូវតែបដិបត្តិតាមទើបបានប្រសើរ ។

## ប្រឹក្សា - ព្រឹក - ត្រឹក្សា

ប្រឹក្សា = ការពិចារណា - ពិគ្រោះគ្នា - ប្រឹក្សាគ្នា ...

ព្រឹក = ព្រឹកព្រហាម - ព្រឹកស្អែក - ព្រឹកល្ងាច ...

ព្រឹក្សា = ឈើទាំងពួង ព្រៃព្រឹក្ស - គោធិព្រឹក្ស... ។

ព្រឹកស្អែកនេះ រដ្ឋាភិបាលនឹងប្រឹក្សាសម្រេចអំពីផលដែលបានមក ព្រឹក្សាជាតិទាំងឡាយក្នុងប្រទេសកម្ពុជា ដើម្បីនឹងកម្រិតពន្ធដារតាម ញាតិ ។

ប្រៀប - ព្រាប - ព្រៀប

ប្រៀប = ប្រៀបធៀបប្រដូច - ប្រៀបផ្ទឹម - និយាយប្រៀបប្រាយ...

ព្រាប = ព្រាបយំថ្ងូរ - ព្រាបសប្រផេះ...

ព្រៀប = ទឹកជន់ព្រៀបច្រាំង - ពេញព្រៀបមាត់ឆ្នាំង... ។

លុះដល់ខែវស្សា ស្រះវត្តយើងមានទឹកពេញព្រៀបហូរហៀរ ប្រៀបដូចជាទឹកទន្លេឡើងលិច មានព្រាបឈ្មោលញីហើរព្រាតព្រោង រកស៊ីនៅលើមាត់ស្រះឥតមានស្រាកស្រាន្ត ។

ប្រុស - ប្រុះ - ប្រេះ - ប្រោស - ប្រោះ

ប្រុស = (បុរស) កូនប្រុសស្រី - ក្មួយប្រុស...

ប្រុះ = ភ្លឺប្រុះព្រោងព្រាយ ភ្លឺប្រុះផ្លុះឡើង...

ប្រេះ = កើតទុក្ខស្ទើរប្រេះទ្រូងស្លាប់–ផ្លែឈើទុំប្រេះ...

ប្រោស = ប្រោសសត្វ–ទានប្រោស–សូមប្រោសប្រណី
យកគ្នាទៅប្រោស...

ប្រោះ = ប្រោះទឹក, ប្រោះត្រី, មើមប្រោះ, ប្រោះឲ្យមានជីវិត..

តាំងតែពីកូនប្រុសនោះធំឡើងកាលណា ម្ដាយកើតទុក្ខស្ទើរប្រេ
ទ្រូង វេលាយប់វាទៅលួចត្រីដែលគេប្រោះទុកបរិភោគ ដូចកាលវាចា
គ្នាយកទៅប្រោសពោលឥតមានមេត្តា ។

## ប្រេង – ព្រេង

ប្រេង = ន. ប្រេងកាត – ប្រេងដូង – ប្រេងល្ង – លាបប្រេង

ព្រេង = គុ. បុរាណ – គូព្រេង – ទ្រព្យព្រេង – ពាក្យ
ព្រេង – ព្រេងព្រឹទ្ធ.... ។

នៅស្រុកស្រែចំការ គេអុជប្រេងកាតឬខ្លាញ់ត្រី ភ័ព្វព្រេងតែ
នៅទីក្រុងធំៗ មានភ្លើងអគ្គិសនី ភ្លឺប្រុះផ្លុះគ្រប់គេហដ្ឋានទាំងអស់

## ផ្កា - ផ្ការ

ផ្កា = ផ្កាខ្ទាប - ផ្សះផ្កាគ្នា - ថ្នាំដំបៅនេះផ្កា....

ផ្ការ = ផ្ការផ្កា - ទៅលេងផ្ការ - ផ្ការនេះស្ដុកស្ដម្ភ - ផ្ការភ្ជាប់ឲ្យជិត - ផ្ការបង្កៀងនឹងទឹកបន្ការ... ។

កាលពីថ្ងៃសៅរ៍មុន មេឃុំបានផ្សះផ្កាអ្នកលក់បន្លែនៅផ្ការ អំពីឈ្លោះវាយគ្នាមានរបួសឈឺផ្កា ជាប់ទាំងជាងផ្ការម្នាក់ធ្វើជាសាកសីទៀតផង ។

## ព - ពរ - ពារ - ពៀរ

ព = ស្រីពកូន - ពពោះ - ពគំនរទុក...

ពរ = ឲ្យពរ - ទទួលពរសព្ទសាធុការ - ពរជ័យ...

ពារ = ការពារ - ពាររបង - ដើរពានពារលើគល់ឈើ...

ពៀរ = ចងពៀរ - មានពៀរវេរានឹងគ្នា - ពៀរពាំទៀរ... ។

បងខ្ញុំបានប្រទះនឹងស្រីម្នាក់ខ្វាក់ភ្នែកទាំងពីរ ពកូនដើរសូមទានគេ

ដូនកាលដើរតាមលើបន្ទា ដូនណាប៉ះនឹងដង្គត់ឈើ បើគេដាក់ទានអ្វីឡើ គាត់លើកដៃសំពះជូនពរសព្ទសាធុការគេ សេចក្ដីវេទនានេះមកពីមាន ពៀរវេរតាមមកផ្ដល់ ពាំនៀរទាំងនោះមិនដែលសាបសូន្យទេ ។

## ពិ _ ពី _ ពីរ

ត្រូវចំណាំពាក្យពីរម៉ាត់ «ពិនឹងពី» ដែលអ្នកសរសេរច្រើនច្រឡំជាញឹកញយ ហើយគិតស្មានថាឥតខុសទៀតផង ។ ពាក្យដែលមាន «ពី» នៅខាងមុខ នោះមានចំនួនតិចជាង «ពិ» នៅខាងមុខ ដូចមានខាងក្រោមនេះ៖

ពិ = ពិការ, ពិគ្រោះ, ពិឃាដ, ពិនិត្យពិច័យ, ពិចារណា ពិចិត្រ, ពិជ័យ, ពិដោរក្ខន, ពិតាន, ពិទូរ្យ, ពិន័យ, ពិបាក ពិពេធ, ពិសាខបូជា, ពិសេស, ពិសោធន៍ ។ ល ។

ពី= ន. ក. ន: (អំពី – ខាង – ឯ) មកពីណា, រូបពីដៃ, សំដីចេញពីមាត់, ពីមុខ, ពីក្រោយ , ពីព្រោះ, ពីពេះ, ពីសីឬពិសី ពីសាឬពិសា, ពាក្យដែលមាន «ពី» នៅពីមុខមានតែប៉ុណ្ណឹង

ពីរ= (ចំនួនមួយនឹងមួយគួបគ្នាត្រូវជាពីរ) ពីរ បី... ។

កាលពីថ្ងៃមុនខ្ញុំបានមកពិគ្រោះនឹងលោក សូមឲ្យលោកពិនិត្យរឿង ស្រពិកាំរ អំពីហេតុដែលគេពិន័យឥតមានពិភាក្សាឲ្យឃើញខុសត្រូវ ាកះ ។

ពេចន៍-ពេជ្រ-ពេជ្ឈ

ពេចន៍ = ន. (ពាក្យសំដី) ពាក្យពេចន៍ - អ្នកបេះពាក្យពេចន៍

ពេជ្រ = ត្បូងពេជ្រ - ចិញ្ចៀនពេជ្រ - ពេជ្រថ្ម...

ពេជ្ឈ = ពេជ្ឈឃាដឬឃាត (អ្នកពិឃាតមនុស្សទោស)... ។

អ្នកបំនួញក្នុងម្នាក់រកស៊ីលក់ត្បូងពេជ្រគ្រប់យ៉ាង បេះពាក្យពេចន៍ ឲ្យចង់ស្តាប់ ចាំរឿងព្រេងជាច្រើន គាត់និទានថា មានព្រះមហា ត្រិយ៍មួយព្រះអង្គទ្រង់ត្រាស់បង្គាប់ពេជ្ឈឃាតឲ្យយកមនុស្សក្បត់ម្នាក់ ពិឃាតឥតមានជំនុំជំរះ ។

ពត់-ពុត-ពុទ្ធ-ពុធ

ពត់ = ពត់ដម្រង់ ពត់ចិត្ត, ពត់ព្រញ....

ពុត = ពុតត្បុត, មានពុត, ដេញពុត, សម្លាប់ពុត

ពុទ្ធ = ព្រះពុទ្ធរូប, ព្រះពុទ្ធ, ធម៌, សង្ឃ, ពុទ្ធដីកា

ពុជ = ថ្ងៃពុធ ផ្កាយពុធ... ។

ពីថ្ងៃពុធ មានកុមារម្នាក់ពុតធ្វើជាឈឺ គេចវេះមិនទៅសាលារៀន បន់តាមលោកទៅលេងផ្សារទិញស្បង់ចីពរទឹងព្រះពុទ្ធរូប កិរិយាក្មេងបែបនេះពិបាកពត់ដម្រង់ណាស់ ។

## ពស់-ពោះ-ពោធិ៍-ពោរ

ពស់ = ពស់វែក, ពស់ព្រលឹត, ពស់ក្រាយ...

ពោះ = ឈឺពោះ, មានពោះពុង, ពោះម៉ាយ...

ពោធិ៍ = ដើមពោធិ៍, ពោធិព្រឹក្ស, ព្រះពោធិសត្វ, ខេត្តពោធិ៍សាត់

ពោរ = ពោរពេញ, ពុះពោរ, កេនពុម្ពមានសៀវភៅពោរពាស

លោកបានហ្វាងកេនពុម្ពឈឺពោះ ពីព្រោះលោកពិសាគ្រុបពោធិ៍សាត់ដែលគេលក់ពោរពាសនៅតាមផ្លូវ ឥឡូវនេះបានឆ្នាំស្រារូបពស់វែកកេតពោះនោះគ្រាន់បើហើយ ។

## ព្រ័ត្រ - ព្រាត់

ព្រ័ត្រ= ព្រ័ត្រក្របី, វេញព្រ័ត្រ, អុំទូកកាត់ព្រ័ត្រ

ព្រាត់= ព្រាត់ប្រាសគ្នា, ព្រាត់មិត្រសង្សារ... ។

ក្នុងឱកាសចូលឆ្នាំខ្មែរមានល្បែងច្រើនយ៉ាង ខ្លះលេងឈូង ខ្លះទាញព្រ័ត្រ ខ្លះបរគោក្របីសេះ អ្នកណាមានទុក្ខទោសព្រាត់ប្រាសនិរាសយ៉ាងណាក៏បានល្ហែនឹងគេដែរ ។

## ព្រុស - ព្រូស - ព្រួស - ព្រោះ

ព្រុស= កិ. ឆ្កែព្រុស, ឆ្កែព្រុសមិនដែលខាំ ។

ព្រូស= ន. ដើមព្រូស, ព្រីងព្រូស ។ ព្រូស. ១. (សូរឮដោយដួល) ដួលព្រូស

ព្រួស= កិ. ព្រួសទឹក ស្តោះព្រួស ។

ព្រោះ= កិ. ព្រោះស្រូវ, ព្រោះថ្នាំ ។ ព្រោះ អា. និ. (ហេតុដ្បិត) ព្រោះឈឺ, ព្រោះខ្ជិល...

ឆ្កែតាព្រូសវាព្រុសឆ្មាមួយអង្គុយនៅប្រគាបដើមព្រូស ឆ្មាភ័យប្រ
ស្រែកព្រួសទឹកមាត់ព្រោះខ្លាចឆ្កែខាំ ។

## ពាក្យទំនឹមទំនៀមបុរាណ

- ស្លូតស្លាប់ វៀចវេរមានភ័ព្វ អាយុយឺនយូរ
- រស់ក៏គាប់ងាប់ក៏គួរ
- ក្របីស្នែងកែក មនុស្សស្រលៀនភ្នែក ក្រពើកំបុតកន្ទុយ
- អន្ទង់វែង រកឆ្នាំងវែង
- បង់ផោយឲ្យមើលប្រាណ ដាំដើងគ្រានឲ្យប្រមាណឆ្នាំង
- ទំពក់វាទៅ ទើបព្នៅវាមក
- លួចគេវាធ្លាប់ដៃ ដេកថ្ងៃវាធ្លាប់ភ្នែក
- ស្រឡាញ់កុំទៅញឹក បើរឭកសឹមទៅម្ដង ៗ
- កាលឈឺយកដំរីទៅបន់ លុះជម្ងឺស្រន់ពងមាន់មួយស្ដាយ
- មានសំពម ទើបឆ្កែវាផុះ
- ឆ្កែព្រុសមិនដែលខាំ
- ដំបៅមិនឈឺ យកឈើចាក់
- ម្នៅ ៗ យកដងព្នៅមកតៀតកៀក

– សូវស្លាប់ប៉ាឲ្យគង់មេ សូវលិចទូកកណ្ដាលទន្លេ កុំឲ្យតែភ្លើងឆេះផ្ទះ

– ទៅឥតគេរក មកឥតគេហៅ

– ទឹកត្រជាក់ត្រីកុម

– កំភ្លាញស្លាប់ពីព្រោះមាត់

– អឹមគៀមស្ងៀមជាជាងស្រដី ស៊ីបេកខ្ជីជាជាងនៅមាត់ទទេ

– កុំទុកចិត្តមេឃ កុំទុកចិត្តផ្កាយ កុំទុកចិត្តស្រីថាគ្មានសហាយ

កុំទុកចិត្តម្ដាយថាគ្មានបំណុល

– ទាហានស្បែកជាប ខ្លាចស្បែកស្វិត

## ភក្តិ–ភក្ត្រ–ភប់–ភព–ភ្លក្ស–ភ្លុក

ភក្តិ ឬ ភ័ក្តិ= ញាតិភ័ក្តិ–មិត្រភក្តិ–ស្វាមីភក្តិ–ជំទប់ភក្តី

ភក្ត្រ ឬ ភក្ត្រ= ព្រះភ័ក្ត្រ–ស្រពព្រះភក្ត្រ (លុបលាងមុខ)...

ភប់= កិ. ជួប–ប្រទះ–ភប់ប្រសព្វ ។

ភព= (ម.ថ.ភប់) សេចក្តីចំរើន–ដំណើរកើត–ពិភពលោក ។

ភ្លក្ស ឬ ភ្លក់= ភ្លក្សសម្ល–ភ្លក់ឲ្យដឹងសាបប្រៃ . . . .

ភ្លុក= ភ្លុកដំរី–បូជាសពមានភ្លុក ៤ នាក់–ភ្លុកខ្មោច . . . ។

ក្នុងកុដិលោកគ្រូចៅអធិការមានភ្លុកដំរីមួយគូ ដំកល់នៅចំព្រះភក្ត្រព្រះមានលោកពិភ័ក្តិរក្សាយប់ថ្ងៃដោយថ្នាក់ថ្នម ។ ក្នុងពិភពលោកនេះត្រូវគប់ប្រសព្វនឹងអ្នកប្រាជ្ញទើបមានភ័ព្វល្អ ។

ព នឹង ផ

ចូរចំណាំអក្សរពីរតួ “ ព នឹង ផ „ ដែលគេច្រើនច្រឡំរបៀបជើ
ជើង ្ល នឹង ្យ ។

ជើង ្ល ត្រូវនៅក្រោមផ–ផ្ល ។

ជើង ្យ ត្រូវនៅក្រោមព–ព្យ ។

ផ្ល= ផ្ល័រផ្លាប់ផ្លិត-ផ្លើញសំពត់-ផ្លុំផ្លរ-ផ្លូវស្រែចំការ-ជញ្ជាំងផ្លុល

ព្យ= ព្យាយាម - ព្យាបាទ - ព្យាបាល - មួយព្យាម - ខ្យល់ព្យុះ -

ព្យួរទោសបរិខ.... ។

លុះដល់ខែភ្ជុំបិណ្ឌ អ្នកស្រុកទៅភ្ជុំគ្នានៅវត្ត ដាក់បិណ្ឌរាល់ព្រឹក ខ្លះព្យាយាមណាស់នៅសំណាក់ក្នុងវត្ត មានបង្កៀនអុជព្យួរភ្លឺព្រោងព្រាត វេលាយប់ ។

## ម៉ដ្ឋ ឬ ម៉ដ្ធ  ម៉ត់ ឬ ហ្មត់

ម៉ដ្ឋ ឬ ម៉ដ្ធ = (ម.ថ.ម៉ត់) (ដែលមានសាច់រលីង-ស្និទ្ធជិត)

. សំពត់សាច់ម៉ដ្ឋ . ម្សៅម៉ដ្ធខៃ...

ម៉ត់ ឬ ហ្មត់ = (អស់រលីង- មិនមាន- មិនសល់) -ស៊ីហ្មត់-

ចោរលួចហ្មត់...

ហ្មត់ចត់= (ស្អាត – បរិសុទ្ធ) – ចិត្តហ្មត់ចត់ – ធ្វើការហ្មត់ចត់

(កុំសរសេរ ម៉ត់ចត់–ម៉ត់ម៉ង យ៉ាងនេះពុំសូវប្រើ) ។

ចិនម៉ៅទៅផ្សារដើររកទិញសំពត់សាច់ម៉ដ្ធល្អ គាត់រើសហ្មត់ចត់ណាស់បានប្រាំគី លុះយកទៅផ្ទះមានចោរលួចហ្មត់ក្នុងយប់នោះទៅ ។

## មាឌ ឬ មាត្រ . ម្រ័ក្សណ៍ . ម្រាក់

មាឌ ឬ មាត្រ= ម.ថ. មាត (វាស់ – ថ្លឹង – រូបរាង – ទម្ងន់

ទំហំ)–មាឌធូក–មាត្រកប៉ាល់–មាត្រប៉ុនគ្នា,

ម្រ័ក្សណ៍= ម.ថ. ម្រាក់–ន. លាបម្រ័ក្សណ៍ ម្រ័ក្សណ៍ខ្មែរ–

ម្រាក់= ន. (ក្មើស្រីទឹនស្រី) –ក្មើទឹនម្រាក់... ។

ក្មើទឹនម្រាក់មាឌប៉ុនគ្នា ប៉ុន្តែ ក្មើប្រុសជាតិជាកិន្គ បានជាគាត់ខ្ញ រលោងដូចម្រ័ក្សណ៍ ។

## យ៉ង់-យ៉ន្ត-យ័ន្ត

យ៉ង់= យប់យន់-យន់ត្របកភ្នែក-យន់កម្លាំង...

យ៉ន្ត ឬ យ៉ន្ត្រ= ម.ថ.យន់ – យន្តដែរ – យន្តហោះ–រថយន្ត ...

យ័ន្ត ឬ យ័ន្ត្រ= ម.ថ.យ័ន – គូរយ័ន្ត – បញ្ចុះយ័ន្ត–យ័ន្តការពារ សត្រូវ...

យប់យន់ណាស់ទៅហើយ គេឮស្នូរយន្តហោះហើរលើអាកាស ខ្ញុំភិតភ័យទាញយកពិតានដែលមានយ័ន្ត មកទទូរគ្របក្បាលការពារ សត្រូវ ។

## យា-យារ-យុត្តិ-យុទ្ធ

យា= យាយី-បីសាចមកយាយី (បៀតបៀន)...

យារ= ក្បួនយារ - សង្រែកយារ...

យុត្តិ ឬ យុត្ត= ត្រឹមត្រូវ - យុត្តិធម៌ (សេចក្តីត្រឹមត្រូវ, ទៀងត្រង់) យុត្តការណ៍ (ហេតុដំណើរដ៏គួរ) យុត្តកិច្ច (កិច្ចត្រឹមត្រូវ)....

យុទ្ធ= ចម្បាំង, សង្គ្រាម, តយុទ្ធនឹងគ្នា... ។

ប្រពន្ធបុរសនោះមិនមែនជាស្រីមាយាទេ គ្នាឈឺយូរយារណាស់មក ហើយ គ្រូទាយថាខ្មោចខាងម្តាយមកយាយី ឥឡូវប្តីខឹងប្តឹងលែង ប៉ុន្តែ ចៅក្រមវិនិច្ឆ័យក្តីនេះដោយយុត្តិធម៌ កាត់សេចក្តីថាត្រូវជានឹងគ្នាវិញ ។

**វត់ - វបិ - វុត**

វត់=រត់លឿន - រត់ចោលស្រុក  រត់ពួន - រត់ទ័ព...

វបិ=រទេះរថ  រថសេះពីរ - ជិះរថទៅលេងកំសាន្ត

វុត= រុតត្រី-យកអង្រុតទៅរុតត្រី... ។

ពីដើមមានរថសេះមួយឬសេះពីរជាច្រើន ឥឡូវនេះគេប្រើរទេះឡានវិញ រត់លឿនជាងរថទាំងអស់ ។ អ្នកស្រែរុតត្រីនឹងអង្រុត បើត្រីបោលកង្ទឹក គេស្ទុះលោតរត់តាមស្ទាក់ពីមុខពីក្រោយទាល់តែរុតបាន ។

## រន្ធ – រុន – រស – រស់

រន្ធ =(ម.ថ.រន់) – រូង – រន្ធកណ្ដុរ – រន្ធបង្រិត

រុន = ពួកកក់ – ដើមរុន – កន្ទុលរុន

រស =(ម.ថ.រស់) – សម្ផស្សប្លែក ៗ ដែលប៉ះពាល់ជិវ្ហាបសាទ

ឲ្យដឹង ប្រៃ, ជូរ, ចត់, អាហារមានរសឆ្ងាញ់

រស់ = មានជីវិតនៅ – រស់នៅ បានរស់ពនមានជីវិតតទៅ ៗ

ចៅរស់ឃើញរន្ធក្ដាមនៅក្បែរគុម្ពរុន កំលូកដៃចាប់បានក្ដាមមួយ យកទៅដុត អាស្រ័យទាំងរស់មានរសជាតិក្រៃលែង ៗ

## រាក – រាគ – រាង – រៀង

រាក = (គឺលេចដោយពន់ខ្លាំងទប់មិនទាន់) – ក្អួតរាកទាម

រាកអាចម៍ – ចុះរាក – រាករូស មាន់រាកស៊ុត...

រាគ = ម.ថ.រាគៈ (គឺតម្រេកត្រេកត្រអាលចំពោះកាម) ចិត្តប្រកប ដោយរាគៈ...

រាង = រាងចាល – រាងលែងធ្វើទៀតហើយ – រូបរាង – រាងស្ដើង....

រៀង = ឈររៀងគ្នា រៀងរាប រៀងរាយ លេខរៀង... ។

រូបរាងគាត់ស្អាំងស្គមរៀងរាបដរាបមក ដោយរាគៈគ្របសង្កត់ ហើយទឹងរោគរាកជានិច្ចទៀតផង ។

## រង់ – រង្គ – រុង

រង់ = រារង់ រង់ចាំបន្តិចសិន...

រង្គ = ម.ថ. រង់ (គ្រឿងជ្រលក់ពណ៌លឿង) – ជ័ររង្គ ...

រុង = រុងរឿង – ថ្កំថ្កើង (កុំសរសេរយ៉ាងនេះរង់រឿង) ថ្កុំថ្កើងឬ ថ្កំថ្កើង ប្រើបានដូចគ្នា ។

បើជាងគំនូរមកដល់ ឲ្យគាត់រង់ចាំខ្ញុំសិន ខ្ញុំនឹងទៅជាមួយបង្ហាញផ្ទះ ដែលមានរង្គលក់ច្រើន រើសយកតែពណ៌ស្រស់ល្អរុងរឿង ។

## រាជ – រាជ្យ

រាជ = (សរសេរឥតជើង «យ្យ») រាជសម្បត្តិ គឺសម្បត្តិ របស់ព្រះរាជាសំរាប់ព្រះអង្គ ដូចជា រាជទ្រព្យ–រាជនារី– រាជបុត្រ – រាជទូត – រាជប្រកាស...

រាជ្យ =សរសេរមានជើង "យ្យ" រាជ្យសម្បត្តិ គឺសម្បត្តិ

សំរាប់រាជ្យឬសំរាប់ផែនដី ពុំមែនសំរាប់ព្រះរាជាទេ ដូចជាព្រះខ័នរាជ្យ -មកុដរាជ្យ – បល្ល័ង្ករាជ្យ -សោយរាជ្យ -ប្រទេសឯករាជ្យ

ព្រះខ័នរាជ្យគេដំកល់ទុកក្នុងព្រះបរមរាជវាំងគឺជាទ្រព្យសំរាប់រាជ្យ ។

«ការចំណាំៈ បើពាក្យ (រាជ) នៅចុងពាក្យត្រូវសរសេរ រាជ ជើង – យ (រាជ្យ) ដូចជាព្រះខ័នរាជ្យ, មកុដរាជ្យ»

## រាន – រៀន – រាប – រៀប

រាន= រានហាល – រានមាន់ – លក់រាន – រានស្រែចំការ

រានភូមិ – មនុស្សរានចំណី – រុករានទន្ទ្រាន...

រៀន= រៀនធ្វើការ – រៀនសូត្រ – រៀនចំណេះវិជ្ជា

រាប= ដីរាប – គោរាប – ចុកពាករាបទាប – រាបស្មើ – រាបសា

រៀប= ទៀប – ហៀប – រៀបស្លាប់ – រៀបនឹងលាគ្នា – រៀបចំ

រៀបខ្លួនប្រាណ...។

សិស្សម្នាក់ចុកពាករាបទាប អង្គុយទន្ទេញមេរៀន នៅរានហាលមុខផ្ទះ ដ៏មានផើងផ្ការៀបដាក់ជាជួរ ។

## រាវ – រៀវ

រាវ= ការចាប់ត្រី ការរកឲ្យឃើញ - ខ្ញាញ់រាវ - បបររាវ - រាវបាន ។

រៀវ= ពងរៀវ, រំពាត់រៀវ, តូចរៀវ

មានចោរម្នាក់ពងរៀវខ្ពស់ ចូលទៅអែបក្បែរផ្ទះបាយគេហើយលូកដៃតាមបន្ទោះជញ្ជាំងរាវរករបស់ទ្រព្យ ក៏ប្រទះបានចានមួយរាវយ៉ាងថ្មី ។

## លក្ខ – លក្ខណ៍ ល័ក្ដ – លាក់

លក្ខ ឬ លក្ស=ម.ថ.ល័ក ន. កំរិត សេចក្ដីកំណត់ ទីមានលក្ខខណ្ឌ – សំដីមានលក្សខណ្ឌ ។

លក្ខណ៍ ឬ លក្សណ៍= ន. ស្រីមានលក្ខណ៍ – ខាតលក្ខណ៍ - លក្ខណៈបរិបូណ៌

ល័ក្ដ ឬ ល័ខ= ន. ល័ខដុំគន្ធ៍ – ល័ខខៀវ – ល័ខខ្មៅ

លាក់=កិ. លាក់របស់, លាក់ពុត, កាប់លាក់ឈើ... ។

មនុស្សនេះខាតលក្ខណ៍ កាត់សក់លាក់ដើងកញ្ជើ និយាយប៉ប៉ាច់ប៉ប៉ោចឥតមានលក្ខខណ្ឌ ហើយស្លៀកខោជ្រលក់ល័ខបែតងខុសពីគេទៀតផង ។

| លក់ - លុក - លង់ - លុង |
|---|

លក់=លក់ទំនិញ - លក់ថ្លៃ - ដេកលក់ - លក់លន់

លុក=លុកលុយ - លុកទ័ព - លុកព្រៃ - ចូលលុកក្នុងផ្ទះ

លង់=ជ្រុលហួសស៊ុន - លង់គំនិត - លង់ទឹក - យូរលង់

លុង=ជីកជាប់ជារលុង-រូង-រូងលុងដី-លុងឈើ - ជីកលុង ។

មេឃុំពិន័យលក់ម្ចាស់សេះដែលធ្វេសប្រហែស លែងសត្វពាហនៈនេះឲ្យលុកលុយស៊ីដំណាំគេ ប៉ុន្តែម្ចាស់អង្វរថា ខ្ញុំបាទបានជាលង់គំនិតគិតតែលុងឈើធ្វើទូកជបម្ជុងគេយកបុណ្យ ។

| រលា - លលា - លលាដ៍ |
|---|

រលា=កិ. ឬ គុ. (រសាយរមួរ រសាយចំណង) ខ្សែរលា

រមុំអំបោះរលា....

លលា=(ម.ថ. លៈលា) គុ. លលាទឹកមាត់, (ធ្លុតទឹកមាត់, ពក្ក-ពាក្កី) អាលលាតែ (និយាយក្លាយជាលេលាក៏មាន)

លលាដ៍= (ម.ថ.លៈលា) ន. (ឆ្អឹងក្បាល) លលាដ៍ក្បាល លលាដ៍ដូង ។

អាលលាតែម្នាក់ កាន់លលាដ៍ដូងនៅដៃ ដើរទៅឈរក្បែរស្រីម្នាក់កំពុងត្បាញសំពត់ ហើយយកលលាដ៍ដូងចោលទៅលើក្តារមួរជាប់រលាអំបោះអស់ ។

## លប់ – លុប – លស់ – ល្អស – លោះ

លប់= ន. លប់លលក. លប់ទទា, ក្រុចជាប់លប់...

លុប = កិ. លុបអក្សរ, លុបមុខ, លុបលាង, សំដីលុបលើ.....

លស់ = កិ. គ្រុនលស់, ដើរលស់ជំហាន, លស់លាគ្រាប្រណី

ល្អស= កិ. ន. ល្អសមែកឈើ, ល្អសអំពៅ ល្អសសំណរល្អសបាយ, រល្អសផ្អុង...

លោះ= កិ. លោះរបស់បញ្ចាំ លោះកែកាំភ្លើង – លោះស្នា ។

ព្រានព្រៃក្រោកពីព្រលឹមលុបមុខយ៉ាងរហ័ស រួចអាញយកលប់

ទៅដាក់លកព្រាប គាត់យកល្ងសចងលប់ភ្ជាប់នឹងកូនរល្ងសមួយដើ
តួប ព្រានទេះចិត្តអាក្រក់ណាស់ឥតមានលស់លាត្រាប្រណីអ្នកណា
ឡើយ អំពើអាក្រក់នេះហើយ បានជាព្រានក្រលំបាកលក់កូនឲ្យទៅ
គេរកប្រាក់លោះកូនពុំបាន ។

| ល្បាង - លៀង - លាប - លាភ - លៀប |
|---|

ល្បាង=កិ. លាងដៃ - លាងចិត្ត - លាងបាប - លាងពៀរ

លៀង=កិ. លៀងជីវិត, លៀងគៀរ, ស៊ីលៀង, លៀងលោម
លៀងអារក្ស

លាប=កិ. លាបប្រេងម្សៅ - យកឈ្មោះគេមកលាប

លាភ=ន. មានលាភ - កើតលាភ

លៀប=ន. ឈើពួកជ្រៃ ដើមលៀប ត្រួយលៀបប្រើជាអន្លក់ ។

មានមួយយប់នោះគេបានអញ្ជើញមន្ត្រីម្នាក់នឹងភរិយាទៅជប់លៀង
ប្តីនឹងប្រពន្ធក៏មុជទឹកដុសលាងខ្លួនប្រាណ រួចស្លៀកពាក់សិតសក់លាប
ប្រេងម្សៅផ្ងូរផង់ គិតថាយប់នេះលាភយើងដល់ហើយ ។

## លាន - លៀន - លិប - លេប

លាន=ន. លានបោកស្រូវ, លានចេតិយ, មុខព្រះលាន

លៀន=កិ. លៀនអណ្ដាត - ក្អែកលៀនត្លៃ.....

លិប=កិ.ន. លិចចុះបាត់ទៅ - ទូកលិច - ព្រះអាទិត្យលិច - លិចកញ្ឆង់លង់កញ្ឆើ - ទិសខាងលិច (ឡិច)

លេប=ចេញពីកំបាំង - កិ. លេចសំដី - លេចដំណឹង - លេចវាល ចូលព្រៃ - គុ. ក្អមលេច - ផ្ទះលេច - ន. កើតដំបៅលេច ។ ចៅលឹមកើតដំបៅលេចលៀនតៃ ដើរទៅឆ្ងាយពុំបាន អង្គុយ នៅលានស្រូវឪពុកវា ទាល់តែថ្ងៃលិចទើបជិះក្របីទៅផ្ទះ ។

## វដ្ដ - វត្ត - វត្ស - វ័ធ - វាត់

វដ្ដ= ម.ថ. វ័តដៈ ដែលវិល - ដំណើរវិលកើតស្លាប់ - វដ្ដសង្សារ (ដំណើរវិលកើតស្លាប់) វដ្ដទុក្ខ

វត្ត= វត្តលោក - សាលាវត្ត - វត្តបដិបត្តិ

វត្សរ៍ ឬ វត្ស =បៀវត្សរ៍ (ប្រាក់ខែឬប្រាក់ឆ្នាំ) សតវត្សរ៍

(ឆ្នាំមួយរយ ឬមួយខួបរយឆ្នាំ...)

វធ =គ្រប់វធគោញាយពោះស្លាប់.... ។

វាត់=វាត់សន្ទូច-វាយវាត់នឹងរំពាត់ ។

បើអ្នកបានធ្វើនាម៉ឺនមានបៀវត្ស ត្រូវតែអ្នកទៅវត្តប្រឹងធ្វើបុណ្យទាន ដើម្បីចាកលះបង់វដ្តសង្សារ កុំធ្វើបាបគេ ជេរពោលវាយវាត់ ដោយអំណាចនៃបុណ្យសក្តិ៍ ក្រែងមានពៀរដូចមន្ត្រីខ្លះស្លាប់វេទនានឹងលង់ទឹក នឹងគ្រប់វធក៏មានដែរ ។

| វា - វារ - វៀរ - វាង - វៀង |
|---|

វា =កូនគោវាស្រែករកមេវា–វារវល់មកពុំបាន

វារ=កូនបេះវារ–ត្រឡាចវារទៅស្លៅវារមក

វៀរ=វៀរចាកទុច្ចរិត–វៀរតែ–វៀរលែង

វាង= ផ្លូវវាង គំនិតវាង–សំដីវាងវៃ

វៀង =(រាជធានី–ក្រុង–វាំង)–វៀងចន្ទន៍ (ក្រុងចន្ទន៍)–វៀងជ័យ

(ក្រុងឬវាំងមានជ័យ)

កូនវាទើបតែនឹងចេះវារ ហើយវាជាមនុស្សមានប្រាជ្ញាវាងវៃណាស់ វាធ្វើដំនួញនៅវៀងចន្ទន៍ វាវៀរចាកទុច្ចរិតទាំងអស់ ពិតមែនតែវ័យនៅក្មេងនៅឡើយ ។

## វាត-វាទ-វិហា-វិហារ

វាត= កិ. វាតទី, វាតមុខ, វាតង៉ារ, វាតទូក ន. វាតពោត (ជម្ងឺខ្យល់)

វាទ= ន. កើតវិវាទនឹងគ្នា (កើតហេតុនឹងគ្នា)

វិហា= ន. (អាកាស - ឋានសួគ៌) ហោះហើរលើវិហា (អាកាស)...

វិហារ= ន. (ការនៅ-អាស្រ័យ) សង់វិហារ បុណ្យឆ្លងវិហារ ។ ជាងវិហារ វាតអំណាចត្រួតត្រាលើជាងឯទៀត ឈ្លោះជេរគ្នា ឥឡូវកើតវិវាទនឹងគ្នា ដល់ទៅតុលាការជំនុំជំរះ ។

## ស-សរ

ស= គុ. សំពត់សក្បុស-សត្រសុស

សរ= កិ. សត្រី - សរកឲ្យឃើញ សរសេចក្ដី - សរហេតុ - សរកេរ្ដិ៍ សរគល់ "ត្រកូលសជាតិ មារយាទសពូជ"

សារ= ន. ព្រញ, កាំ, ស្ដេចផ្ញើសារ, កូនសារ, សារដ៏យ

សារ= កិ. រៀតទឹកឃើញ, សារជាតិ, (ជីវជាតិ) សារញាណ បត្ដសារសន៍, សារសើរមារយាទ, សារសេរអក្សរ សារសៃសូត្រ, សសារផ្ទះ, ដើរសសៀរតាមជញ្ជាំង ។

អ្នកនេសាទត្រី យកស្នូមួយមានមុខស្រួចសដូចសំឡី ទៅសត្រីកន្ធីបឹង ។ យក្ខិនីត្រូវសារកវ្យែដីវិត ហើយសារជាតិថា កាលពីមុនខ្លួនប្រព្រឹត្តអំពើអាក្រក់ បានពិឃាតសត្វជាច្រើន ។

## ស័ក - សក្តិ - សាក់

ស័ក= ន. កាល, សម័យ, ឯកស័ក, ទោស័ក, ឆ្នាំជូត សំរិទ្ធិស័ក, ឆ្នាំឯកស័ក, ខាលទោស័ក

សក្តិ ឬ ស័ក្តិ= ន. មានសក្តិ, ស័ក្តិតូច, សក្តិធំ, ថាំស័ក្តិសិទ្ធិ (ពូកែធុតធាប់)

## សត្ត-សត្វ-សាត់

សត្តឬសត្វ= (ម.ថ. ស័ត) សត្តឃាត ឬ សត្វឃាត (ការសម្លាប់សត្វ) ផ្សារសត្តឃាត (ផ្សារពិឃាត) សាប់សត្វ-ព្រះពោធិសត្វ... ។

សាត់= (ប៉ើង-ហើរតាមខ្យល់-អណ្តែតតាមទឹក) សាត់អណ្តែត, សាត់ព្រាត់, សំណាត់សាត់តាមខ្សែទឹក... ។

នៅខេត្តពោធិ៍សាត់មានទីពិឃាតសត្វមួយ គេយកសាប់សត្វទាំងនោះទៅលក់ឯផ្សារឲ្យបណ្តាជនគន់គ្រើន ។

## សប់-សប្ត-សព-សព្វ

សប់= សប់ទឹក, សប់គន់, មនុស្សប្រសប់, បេះដូងពុំស្មើទីន ប្រសប់មួយ...

សប្តឬសប្ត-សប្ដិ= យល់សប្ត, យល់សប្តិ, យល់សុបិន...

សព= បូជាសព ដឹកលល់សព លើកសព...

សត្វ= សត្វគ្រប់, សត្វសាយ ប្រសព្វមុខ ទឹកហូរ

ប្រសព្វគ្នា...

លោកគ្រូព្រះសត លោកប្រសប់ការងារគ្រប់សត្វទាំងអស់ ការណ៍ក្រយ៉ាងណាក្តី ក៏លោកដោះស្រាយបានស្រួលឥតទើសទាស់ឡើយ ពីយប់មិញខ្ញុំយល់សប្តិឃើញលោកនិមន្តមកវត្តវិញ ។

## សា - សារ

សា– កិ. សាកន្ទួល, សាស្រូវ, សាមកវិញ ដើរសាចុះ សាឡើង ។ ន. ស្រូវសា, ផ្ទៀកសា (ដែលដុះពីគល់ឡើងវិញ) សាគ្រី (ក្លា) ឈ្មោះបែកសា...

សារឬសារៈ= ខ្លឹមសារ, សរសេរសារផ្ញើទៅ (សំបុត្រ) ឥតសព្ទ ឥតសារ សារព្រឹក្ស (ឈើមានខ្លឹម) សារគ្រោ, ដំរីសារ, សារពាង្គកាយ, សារពើ សារពេជ្ញ, សារភាព...

ដំរីសារស្ទាប់យកបង្គោរបាំង លុះបាំងមិនជិតក៏ខឹងប្រឡោតឈ្មោះ ដេរគេជិតខាងបែកសាយាមោ ។

## សុក - សុក្រ - សុខ

សុក= ន. សុកកូន, ទឹកប់សុក, បងប្អូនប្រជាក់ទងសុក...

សុក្រឬសុក្ក = ផ្កាយសុក្រ, ថ្ងៃសុក្រ...

សុខ =គុ. សុខសប្បាយ, សុខក្សេមក្សាន្ត, សុខសាន្ត, សុខទុក្ខ ។

កូនលោកកើតពីថ្ងៃសុក្រ  អាចារ្យទឹងឡបបង្គាប់ឲ្យយកសុកទៅកប់ខាងទិសនិរតី  ដើម្បីឲ្យទារកទឹងមាតាបានសេចក្ដីសុខសប្បាយ អាយុយឺនយូរថែមទាំងឲ្យឈ្មោះចៅសុខទៀតផង ។

## សូ - សូរ - សូរ្យ

សូ= ន. (ខ្សែមាសឬប្រាក់មានសណ្ឋានជាច្រវ៉ាក់) ខ្សែសូ...

សូរ= (សព្ទសម្លេង) សូរផ្គរ, សូរសព្ទ, សូរសៀង...

សូរ្យ= ន. (ព្រះអាទិត្យ) សូរ្យសែង (ពន្លឺព្រះអាទិត្យ)
សូរ្យគ្រាស (ដំណើរដែលរាហូចាប់ឬបាំងព្រះអាទិត្យ) ។

កាលពីថ្ងៃអាទិត្យមុនមានសូរ្យគ្រាស គេបានវាយស្គរវាយជួងឮសូរ

ពន្លគ្រប់វត្ត ស្រីខ្លះពាក់គ្រឿងអលង្ការ មានទំហូទឹងខ្សែសូជាដើម

អន្ទុយថ្ងាយបង្គំសូម្បគ្រាសនៅកនហាលមុខផ្ទះ ។

សូន – សូន្យ

សូន = កិ. សូនរូបក្រមួន, សូនកុលិកា..... ។

សូន្យ = គុ. សូន្យសុង, សូន្យសោះ, លេខសូន្យ... ។

លោកមេឃុំ បាននិយាយទឹងជាងស្មិតពីខែមុន ឲ្យយកជ័ដជួសូន

ធ្វើរូបហនុមានមួយ ឥឡូវនេះជាងនោះ កំបាត់សូន្យឈឹង ពុំមានដំណឹង

អ្វីសោះ ។

សួ – សួរ – សួគ៌

សួ = កិ. សួស្ដី – សួស្ដានប៉ុស្ស – សួព្រ័ត្រ....

សួរ = កិ. សួរនាំ – សួរដំណឹង – សួរមាត់សួរពាក្យ – សំនួរ...

សួគ៌ = ន. ទេវលោក – បានសួគ៌ – ផ្លូវសួគ៌... ។

លោកអាចារ្យសួរគេពាទទៅអ្នកជិតខាងថា សួស្ដីដែលអ្នកពល់គ្នាសួ

ទៅកាន់បានសួគ៌បាន គេទីពឹងលើផ្លូវណា ធ្វើយថាទីពឹងផ្លូវធម៌ ។

## សំរាន្ត - សំរិត - សំរិទ្ធិ

សំរាន្ត = លោកសំរាន្ត ឬ លោកសម្រាន្ត - ជម្ងឺស្រាកស្រាន្ត ជាសុខសាន្ត...

សំរិត = (គ្រឿងស្អាតឲ្យបរិសុទ្ធ) - សំរិតសំរាំង - អក្សរសម្រិត...

សំរិទ្ធិ = (សេចក្តីសម្រេច - ចំរើន) សំរិទ្ធិជ័យ - ផលសំរិទ្ធិ... ។

បូលឯងសម្រាកបន្តិចចុះ លុះដល់ម៉ែគាត់ក្រោកពីសម្រាន្ត ឯងយកផលសំរិទ្ធិនេះដាក់អក្សរសំរិតឲ្យពេញទៅជូនគាត់កុំខាន ។

## ស្និត - ស្និទ្ធ - ស្នើ - ស្នើរ

ស្និត = ន. ស្និតបេក - ស្និតសិតបៃ - ស្និតស្នែង...

ស្និទ្ធ = (ស្រឡាញ់អស់ពីចិត្ត) មនុស្សស្និទ្ធនឹងគ្នា - ស្និទ្ធស្នាល ស្និទ្ធស្នេហ៍...

ស្នើ = (សូមឲ្យដឹងសិន) ស្នើការ - ទូលស្នើរ...

ស្មើរ= (ស្រពាប់សង្កាត់) ហើយកតាមស្មើ - មុំមួយស្មើ - (មុំពីរ សន្ទឹក)...

មានសិស្សពីរនាក់ស្ទុះស្ទាលទឹងគ្នាណាស់ ពីល្ងាចមិញនាំគ្នាទៅទិញស្មិតស្មិតថៃ រួចទិញបេកនួនមួយស្មិតទឹងម្ហូបស្មើរយកទៅស្មើការទឹងគេ ក្រែងបានសម្រេចដូចប្រាថ្នា ។

| ស្មា - ស្មារ - ស្បូវ - ស្មោះ |
| --- |

ស្មា= ន. ស្មាគាង - ស្មាក្តី - ស្មាគម.....

ស្មារ= ស្មារតី ឬ ស្មារ្តី - មានស្មារតី - ស្មារលោទោស....

ស្បូវ= (កំណាញ់) - ស្មូរជន - ចិត្តស្មូរជន....

ស្មោះ= ស្មោះងារ (ខ្ជីខ្ជា) - ស្មោះសរ (សេចក្តីរកពាយ) - ស្មោះស្ម័គ្រ....

បុរសដែលមកពីថ្ងៃសុក្រ មុខពា ស្មាគាង ស្មារតីវង់ ចិត្តស្មូរជន ឥតមានសេចក្តីស្មោះសរទឹងអ្នកជិតខាងឡើយ ។

## ស្រុស-ស្រុះ-ស្លេស្ម-ស្លេះ

ស្រុស= កិ. ស្រុសអន្ទក់ ស្រុសមាន់....

ស្រុះ= កិ.ស្រុះស្រួលគ្នា ស្រុះគ្នាដូចស្រមោច....

ស្លេស្ម= (ទឹករំអិលការចេញតាមបំពង់ក) ក្អកថ្លាក់ស្លេស្ម....

ស្លេះ= (ឈប់បង្អង់ទុក) ត្រូវស្លេះសេចក្តីនេះទុកសិន... ។

ជីដូនចៅមាន គាត់ក្អកថ្លាក់ស្លេស្មមានឈាម កូនចៅគាត់ស្រុះគ្នាណាស់ ខ្លះរត់រកថ្នាំ ខ្លះរកស្លឹកឈើណាដែលត្រជាក់យកមកស្ងោរ ឬស្រុសយកទឹកឲ្យគាត់ពិសាឲ្យបានបាត់ក្អក ។

## ហត្ថ-ហាត់-ហា-ហារ

ហត្ថ= ន. (ដៃ) - ហត្ថខ្នាត - មួយហត្ថ - ហត្ថកម្ម....

ហាត់= កិ. ហាត់គុន - ហាត់ភ្លេង - ហាត់ប្រាណ...

ហា= កិ. ហាមាត់ សៀសហាលថ្ងៃហា...

ហារ= ចែក-លេខហារ-ដើរហារ... ។

នៅសាលាហត្ថកម្ម មានហត្ថខាតគ្រប់យ៉ាងសំរាប់រស់ មានកន្លែងហាត់ប្រាណ មានបន្ទប់រៀនសំរាប់សិក្សាខាងអក្សរ និងលេខ បូក សង គុណ ហារ ។

## ហោ - ហោរ

ហោ= ឈើគុសមួយហោ ដេរប្រយ័ត្នកុំឲ្យហោ (ជ្រួញ)...

ហោរ= (ហោរា)-កូតនៅហោរ ទោរនៅជាង...

មានហោរម្នាក់នៅខាងលិចហោត្រវត្តយើង ល្បីឈ្មោះខាងទាយ ជុតណាស់ មនុស្សទៅមករកគាត់ហូរហៃពុំសូវដាច់ទេ ។

## ហ្ម - ហ្មត់

ហ្ម= ន. (ពេទ្យ) - ពេទ្យហ្ម - ហ្មមើលជម្ងឺ - ហ្មដំរី ហ្មថាវ

(ហ្មចាស់ទុំ ជាគ្រូលើហ្មដំរីក្នុងពួកមួយ ៗ)

ហ្មត់= (អស់) - ភ្លើងឆេះហ្មត់, ហ្មត់ចត់ (ត្រឹមត្រូវ)

ហ្មត់ហ្មង (ឥតសៅហ្មងឬសុទ្ធសូន្យ) ។

ហ្មថាវបញ្ញត្តទៅហ្មទាំងឡាយឲ្យខំធ្វើការដោយហ្មត់ចត់ កុំធ្វេសប្រហែសឲ្យសោះ បើមានរោគផ្សេង ៗ ត្រូវរត់រកពេទ្យហ្មយ៉ាងប្រញាប់ ។

## ពាក្យទំនឹមទំនៀមបុរាណ

- ចូលស្ទឹងតាមបត់
- អណ្តាតជាអាទ៌កន្ទង អស់ទ្រព្យធនផងពីព្រោះអណ្តាត
- ដឹងឆ្វើយផ្សិតដង កូនឆ្គងផ្សិតមេបា
- ឈើពុកកុំអង្គុយលើ
- អួសទូកកុំឲ្យលំអាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក
- ស្រឡាញ់ខ្លួនឲ្យស្ងួនចំណី ស្រឡាញ់ស្រីឲ្យស្ងួនចិត្ត
- ស្រឡាញ់មេរំពេជល់កូន
- ឈើផ្លែច្រើនចាញ់ស្លឹក ត្រីច្រើនទឹកល្អក់ពុំជា
- កាន់កពស់កាន់ឲ្យខ្ជាប់ ក្រែងក្រឡាប់ខាំឯប្រាណ

– ទឹកហូរមិនដែលហត់ មនុស្សស្បថកុំឲ្យជឿ

– ត្រីមួយត្រក ស្អុយតែមួយ ស្អុយទាំងអស់

– ពងមាន់កុំជល់នឹងថ្ម

– ធ្ងន់នៅថ្មក្រនៅក្ដី

– ប្រាជ្ញពុំស្មើប្រាប ចាក់ស្លឹកត្រចៀកខ្លួន ពុំស្មើឡេមឡឹម

– គយជេកជាស់គយឲ្យអង្ករ

– កុំបំពត់ស្រឡៅ កុំប្រដៅមនុស្សខូច

– ទំពាំងស្នងឫស្សី

– ដំរីជុះកុំជុះតាមដំរី

– ដើរឲ្យមានបី ស្រដីឲ្យមានបួន

– ស៊ូវបង់ប្រាក់មួយថង់ កុំឲ្យបង់ពាក្យ

– ផ្ទះធំស្រណុក ព្រោះលក្ខណ៍ស្រីជា

## ហ្លួង – លួង

ហ្លួង = ន. (ព្រះរាជា)= ហ្លួងយាង – ហ្លួងឧបរាជ ហ្លួងសេនានុរក្ស (ងារតូចជាងព្រះ) ហ្លួងព្រះបាទ... ។

ល្អ= កិ. លួងលោម លួងលួងឲ្យស្រួលចិត្ត... ។

ព្រឹកស្អែកនេះ ហ្លួងទ្រង់យាងចេញប្រពាតរង្វាន់ដល់ពួកក្រុមពិជ័យសង្គ្រាម ។ ហ្លួងស្តេចចូលទៅក្នុងព្រះមហាដំណាក់ លួងលោមព្រះមហេសីមុនទ្រង់ចេញទៅក្រសាលឯព្រៃព្រឹក្ស ។

## អ_អរ_អំណរ_ល្អ_លំអ

អ= ន. បាយអ (កំបោរថ្ម ខ្សាច់លាយទឹក)–ផ្ទុំបុំអ (ប៉ុបប៉ុស)...

អរ= កិ. (មានអំណរ) អរគុណ–អរបានទ្រព្យ...

អំណរ= ន. (សេចក្តីអរ) មានអំណរ...

ល្អ= គុ. ចិត្តល្អ–រូបល្អ–អំពើល្អ...

លំអ= ន. (សេចក្តីល្អ)–លំអរូប...

ជាងយកកំបោរថ្មនិងដីខ្សាច់លាយទឹកធ្វើជាបាយអ ហើយយកស៊ីម៉ង់ត៍លាយបញ្ចូលខ្លះទៀតឲ្យបានជាប់ល្អ ដើម្បីឲ្យម្ចាស់ផ្ទះត្រេកអរទទួលការរបស់ជាង ។

## អប្ប-អ័ត្ថ-អាប់

អប្ប= ម.ថ. អប្បៈ (តិច-ស្តួចស្តើង) អប្បទ្រព្យ-អប្បបញ្ញា

អប្បលាភ...

អ័ត្ថ ឬ អ័ត្រ = (ពពកខាប់) - ចុះអ័ត្ថ-ងងឹតអ័ត្ថ-ធ្លាក់ហុយ

អ័ត្ថ អ័ត្ថអួ...

អាប់= (ដែលអន់ឬតិចពន្លឺ)-អាប់គំនិត-អាប់ជាតិ-អាប់

ប្រាជ្ញា (ខ្សោយ) -អាប់មុខ-អាប់ស្មើ...

ព្រឹកមិញចុះអ័ត្ថពេញទន្លេ នាំឲ្យអ្នកអុំឬបែវទូកអាប់ប្រាជ្ញាទីង

ងងឹតអ័ត្ថនោះ រកផ្លូវស្ទើរតែពុំឃើញ ។

## អសារ-អាសន្ន-អាសា

អសារ= (ដែលឥតខ្លឹម-ប្រយោជន៍-ឥតអំពើ)-របស់

អសារឥតការ-សំដីអសារឥតការ...

អាសន្ន= (ជិត) -ភ័យអាសន្ន (ភ័យជិត) មានអាសន្ន-

...ះណ្ដាះអាសន្ន... ។

អាសា=ន. បំណង-សង្ឃឹមៈមានអាសា ។ អាសា-ប្រើជាៈ ន. ឬគុ.

បានសេចក្ដីថា «ការជួយឈឺឆ្អាលដោយស្ម័គ្រចិត្តៈយកអាសាគេ»។

កាលពីខែដាប់ទៅ គាត់មានអាសន្ន បានតែមកខ្ចីប្រាក់ខ្ញុំមួយរយ

រៀល ខ្ញុំក៏យកអាសាគាត់ ដល់គ្រប់សន្យាហើយ ខ្ញុំទៅទារទាចខ្ចប្រាក់

អសារផតការ គាត់ថាកុំកាលអាសន្នពេក អញមិនរត់ទៅណាទេ ។

## អាទិ-អត្ថ-អារ្យ

អាទិឬអាទ៏= ម.ថ.គាត.ន. (ដើម-ដើមដំបូង) នាំអាទ៏

(នាំផ្ដើមមុន)-ធម្មតាអ្នកជាជាតិ កាលគេអាទ៏

ឲ្យគិតគូរ កុំខ្ជិលបដេកទទូរ ដល់ថ្ងៃរះពេញពន្លឺ ។

អត្ថ= ម.ថ.អ័ត.ន. (ប្រយោជន៍-សេចក្ដី-ពាក្យប្រែ

ស្រាយ-រឿងហេតុ) ស្គាល់អត្ថ(ស្គាល់សេចក្ដី)-

រៀនអត្ថ (រៀនសេចក្ដីអធិប្បាយ)...

អារ្យ= (អរិយ) (ប្រសើរ ត្រឹមត្រូវ-សុភាព)=អរិយធម៌ឬ-

អារ្យធម៌ (ធម៌ដែលនាំឲ្យចំរើន សេចក្ដីសុខចំរើន)...

រៀនអត្ថហ្មត់ចត់ណាស់ បេះធមិអាឡ្យក៏ជ្រៅជ្រះណាស់ដែរ តែនៅភ្ញាត់ម្ដង ៗ ។

## បារម្ភ – អារម្មណ៍

បារម្ភ=(ការផ្ដើម–សេចក្ដីផ្ដើម–ការនាំអាទ៍) ខ្ញុំមានបារម្ភខ្លាំង ទឹងការណ៍នោះអ្នកកុំបារម្ភឲ្យសោះ ខ្ញុំធានាជួយ ឲ្យខាងតែបាន ។

អារម្មណ៍= (គ្រឿងតោងរបស់ចិត្ត–គំនិត–ការដឹង) អារម្មណ៍ មិនល្អមិនទៀង – ចាប់អារម្មណ៍ (ចាប់ចិត្ត អធ្យាស្រ័យ...) ។

អ្នកកុំបារម្ភទឹងការណ៍ដែលអ្នកពឹងខ្ញុំឲ្យជួយគិតគូរនោះ គេទឹងសម្រេចដូចចិត្តអ្នកប្រាថ្នា ប៉ុន្តែអ្នកកុំទាស់អារម្មណ៍ទឹងកិរិយារបស់អ្នក ត្រូវសន្ដោសប្រោសប្រណីពីព្រោះគ្នាបានជាប្រព្រឹត្តហួសទៅហើយ ។

## អាប – អាបម៍

អាប= . (ហ៊ាន – ធ្វើបាន – មិនរួញរា) – អាចធ្វើបាន – អាចថាបាន... ។

អាបម៌= ម.ថ. អាថ៌ – (អាហារចាស់) – អាថ៌មន –
អាថ៌សត្វ...

អាថ៌ល័ខអាចកួរភ្ជាប់ស៊ីផ្សេងៗបាន ដូចជាមៀនកាំបិត កណ្ដ
ជាដើម មិនអាចនឹងរង្គោះរាយទេ ។

## អា – អារ – រអា

អា= បុរិសសព្វនាម ជាពាក្យពាបឥតគួរសម – អាណា
អានេះ – អាឯង...

អា= គុ. ស្រីអា – មេគោអា (ឥតកូន)...

អារ= កិ. កាត់ – បំបែកៗ អារឈើ – អាររំលំ – អារត្រៀក

រអា= កិ. ឬ គុ. – បេញទ្រាន់ខ្ជាំងៗ ចិត្តរអា – ខ្ញុំរអា-
ហើយ រអាសាច់ (ទ្រាន់សាច...)។

អាពោរនេះគេធ្វើខុសកំពុសវ៉ាច្រើនលើគមកហើយ ប៉ុន្តែអាសោះ
ឥឡូវនេះខ្ញុំមិនហ៊ានអារកាត់សេចក្ដីនេះទេ ។

រោងពុម្ពឧរិយ
នៅខាងត្បូងផ្សារអូរឬស្សីសង្កាត់លេខ៥

តម្លៃ ១៥៛